ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# ព្រឹត្តិបត្រប្រចាំត្រីមាស

## ត្រីមាសទី៤ ឆ្នាំ២០២៣



ចេញផ្សាយតាមប្រកាសលេខ
ធ៦-០១១-១២៣ ប្រ.ក
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

លេខ ៧៧

### បោះពុម្ពផ្សាយដោយ

## ធនាគារជាតិ នៃ កម្ពុជា

| | | |
|---|---|---|
| អាសយដ្ឋាន | : | ឡូត៍លេខ៨៨ ផ្លូវលេខ១០២ កែងនឹងផ្លូវលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ប្រអប់សំបុត្រ | : | ២៥ |
| ទូរស័ព្ទ | : | (៨៥៥) ២៣ ៧២២ ៥៦៣ |
| ទូរសារ | : | (៨៥៥) ២៣ ៤២៦ ១១៧ |
| គេហទំព័រ | : | www.nbc.gov.kh |

*********

### Published by

## National Bank of Cambodia

| | | |
|---|---|---|
| Address | : | #88 Street 102 Corner Street 19, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia. |
| P.O.BOX | : | 25 |
| Phone | : | (855) 23 722 563 |
| FAX | : | (855) 23 426 117 |
| Website | : | www.nbc.gov.kh |



| គណៈកម្មការព្រឹត្តិបត្រ | | Review Commission | |
|---|---|---|---|
| - ឯកឧត្តម ថា យ៉ាវ | ប្រធាន | H.E. Tha Yao | Chairman |
| - ឯកឧត្តម ស៊ុំ សន្និសិទ្ធ | និពន្ធនាយក | H.E. Dr. Sum Sannisith | Chief Editor |

# អារម្ភកថា



**លោកជំទាវបណ្ឌិត ជា សិរី**
**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

### ប្រិយមិត្តអ្នកអានជាទីមេត្រី!

សេដ្ឋកិច្ចពិភពលោកបានឆ្លងកាត់ឧបសគ្គជាបន្តបន្ទាប់ ក្រោយពីបានងើបឡើងវិញពីវិបត្តិកូវីដ-១៩។ ការបន្តដំឡើងអត្រាការប្រាក់គោលដើម្បីកាត់បន្ថយអតិផរណា ការរួមតូចនៃលំហនយោបាយសារពើពន្ធ ការកើនឡើងហានិភ័យនៃការបែងចែកភូមិសាស្ត្រនយោបាយ វិបត្តិអចលនទ្រព្យ និងភាពទន់ខ្សោយនៃតម្រូវការក្នុងស្រុកនៅប្រទេសចិន បានដាក់សម្ពាធលើពាណិជ្ជកម្ម ការប្រើប្រាស់ និងការវិនិយោគសកល។ ក្នុងស្ថានភាពនេះ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានប៉ាន់ស្មានថាមានកំណើន ៣,២% ទាបជាងឆ្នាំ២០២២បន្តិច។

ការថមថយកំណើនសេដ្ឋកិច្ចពិភពលោក ជាពិសេស ដៃគូពាណិជ្ជកម្មកម្ពុជា បានដាក់សម្ពាធលើការនាំចេញផលិតផលកាត់ដេរ ស្របពេលដែលវិស័យសំណង់និងអចលនទ្រព្យនៅទន់ខ្សោយ ។ ទោះយ៉ាងណា បច្ច័យអវិជ្ជមានទាំងនេះ ត្រូវបានប៉ះប៉ូវដោយការបន្តការងើបឡើងនៃវិស័យទេសចរណ៍ ការរក្សាបានកំណើនខ្ពស់នៃការនាំចេញផលិតផលមិនមែនកាត់ដេរទាំងក្នុងវិស័យកម្មន្តសាលនិងកសិកម្ម និងការកើនឡើងតម្រូវការក្នុងស្រុក ដែលបានរួមចំណែកគាំទ្រសេដ្ឋកិច្ចកម្ពុជាឱ្យកើនឡើងក្នុងអត្រា ៥%។ ក្នុងត្រីមាសទី៤ អតិផរណាបានថមថយមកវិញត្រឹម ៣,១% ដែលបានរួមចំណែកនាំឱ្យអតិផរណាជាមធ្យមក្នុងឆ្នាំ២០២៣ មានកម្រិតត្រឹម ២,១% ដោយសារការថយចុះថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារ ជាមួយនឹងការបន្តរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ក្នុងកម្រិតជាមធ្យម ៤.១១៩ រៀលក្នុង១ដុល្លារអាមេរិក។ ជាមួយគ្នានេះ ទុនបម្រុងអន្តរជាតិរបស់កម្ពុជាក៏ត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្ននិងមានភាពបត់បែន ព្រមទាំងបានគរពូនឱ្យមានកម្រិតខ្ពស់គ្រប់គ្រាន់ ដែលបានពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិន និងបម្រើដល់ការអនុវត្តនយោបាយរូបិយវត្ថុ។

ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់ និងមានវឌ្ឍនភាពជាលំដាប់ ដែលធានាដល់ការរក្សាចីរភាពហិរញ្ញប្បទាននិងសេវាហិរញ្ញវត្ថុចាំបាច់នានា ក្នុងការរួមចំណែកគាំទ្រសកម្មភាពសេដ្ឋកិច្ច។ ស្ថិតក្នុងបរិការណ៍នៃការវិវឌ្ឍរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រព័ន្ធទូទាត់ត្រូវបានបន្តអភិវឌ្ឍជាប់ជាប្រចាំ ដើម្បីក្លាយជាមុខព្រួញរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។ ក្នុងទិសដៅនេះ ប្រព័ន្ធទូទាត់កម្ពុជាកំពុងរួមចំណែកយ៉ាងសកម្មក្នុងការសម្រួលការដោះដូរ និងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការជំរុញការទូទាត់កាន់តែមានភាពងាយស្រួល សុវត្ថិភាព ចំណាយទាប និងអាចធ្វើប្រតិបត្តិការឆ្លងពីគ្រឹះស្ថានមួយទៅគ្រឹះស្ថានមួយបានដោយប្រសិទ្ធភាព។ លើសពីនេះ ប្រព័ន្ធទូទាត់កម្ពុជាត្រូវបានតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ និងប្រព័ន្ធទូទាត់អន្តរជាតិជាបន្តបន្ទាប់ ដើម្បីផ្តល់លទ្ធភាពកាន់តែទូលំទូលាយក្នុងការទូទាត់ដល់ប្រជាជនកម្ពុជា និងទេសចរអន្តរជាតិផងដែរ។

ធនាគារជាតិនៃកម្ពុជា ក៏បានបន្តយកចិត្តទុកដាក់លើការជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព តាមរយៈការបង្កើតផែនទីមគ្គុទ្ទេសក៍ហិរញ្ញវត្ថុប្រកបដោយចីរភាព ការគាំទ្រការអនុវត្តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការចូលរួមបង្កើតប្រព័ន្ធវដ្តករសាស្ត្រសម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាព និងការពង្រឹងកិច្ចសហប្រតិបត្តិការនានាជាមួយស្ថាប័នទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិលើការជំរុញការផ្តល់ហិរញ្ញប្បទានបៃតង។

## ប្រិយមិត្តអ្នកអានជាទីមេត្រី!

ធនាគារជាតិនៃកម្ពុជាមានកិត្តិយសសូមផ្សព្វផ្សាយព្រឹត្តិបត្រប្រចាំត្រីមាសទី៤ ឆ្នាំ២០២៣ ដោយរួមបញ្ចូលនូវព័ត៌មានសំខាន់ៗ ដូចជា៖ i/-ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធធនាគារ ii/-បទប្បញ្ញត្តិថ្មីៗ និង iii/-សេចក្តីប្រកាសព័ត៌មាន ជាដើម។ ព័ត៌មានទាំងនេះក៏នឹងផ្តល់ជាធាតុចូលដល់ប្រិយមិត្តអ្នកអានទាំងអស់ ក្នុងការពង្រីកចំណេះដឹងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាគាំទ្រដល់ដំណើរការរៀបចំគាក់តែងនយោបាយពាក់ព័ន្ធផ្សេងៗ។

ឆ្លៀតក្នុងឱកាសនេះ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា ឱ្យរីកចម្រើនឡើងជាលំដាប់ និងបោះជំហានទៅមុខយ៉ាងស្វាហាប់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយភាពរឹងមាំ ចីរភាព និងបរិយាបន្ន។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មាតិកា


**អារម្ភកថា**........................................................................................ i-ii

**ផ្នែកទី១: រូបថត និងសុន្ទរកថារបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា**

១.១. សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ថ្លែងក្នុងកម្មវិធីលៀងសាយភោជនប្រចាំឆ្នាំ២០២៣ ......... ១

១.២. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយសៀវភៅ ស្តីពី "ដុល្លាររូបនីយកម្មនៅកម្ពុជា៖ ទំនាក់ទំនងផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច" ........................................................................ ៤

១.៣. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនតាមយ្យូអរកូត" រវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន AliPay Connect Pte. Ltd.................................. ៨

១.៤. សុន្ទរកថាបើក លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០២៣ ........................................................................................ ១១

១.៥. សុន្ទរកថាបើក លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី១០ ស្តីពី "ហានិភ័យអាកាសធាតុ និងអន្តរកាលឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង"..................... ១៤

១.៦. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយគណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ ........................................................................................ ២០

១.៧. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងកម្មវិធីកិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន-ជប៉ុន ឆ្នាំ២០២៣ ........................................................................................ ២២

១.៨. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងកម្មវិធីប្រកាសដាក់ឱ្យដំណើរការប្រតិបត្តិការទូទាត់ឆ្លងដែនតាមយ្យូអរកូត (QR Code) ជាផ្លូវការរវាងប្រព័ន្ធទូទាត់បាគងរបស់ធនាគារជាតិនៃកម្ពុជា និងបណ្តាញទូទាត់របស់ក្រុមហ៊ុន UPI ............................................ ២៦

**ផ្នែកទី២: សេចក្តីប្រកាសព័ត៌មាន**

២.១. សេចក្តីប្រកាសព័ត៌មាន ស្តីពី ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ ស្តីពីការទូទាត់ឆ្លងដែនតាមយ្យូអរកូត រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន ........................................................................ ២៩

២.២. សេចក្តីប្រកាសព័ត៌មាន ស្តីពី ធនាគារជាតិនៃកម្ពុជា ចាប់ដៃគូជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដើម្បីជំរុញហិរញ្ញប្បទានបៃតង គាំទ្រសកម្មភាពអាកាសធាតុ ........................ ៣០

## ផ្នែកទី៣: សកម្មភាពថ្នាក់ដឹកនាំ

៣.១. លោកជំទាវបណ្ឌិត ជា សិរី អមដំណើរសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ចូលក្រាបថ្វាយបង្គំគាល់ ព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី................................................ ៣៣
៣.២. លោកជំទាវបណ្ឌិត ជា សិរី និងឯកឧត្តម SAITO Ken អញ្ជើញចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ ស្តីពី "ការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូត"........................... ៣៥
៣.៣. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំគណៈប្រតិភូចូលរួមក្នុងមហាសន្និបាតពេញអង្គប្រចាំឆ្នាំ២០២៣ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (WB) នៅទីក្រុងម៉ារ៉ាកិច ប្រទេសម៉ារ៉ុក............................................................................ ៣៦
៣.៤. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំគណៈប្រតិភូ ចូលរួមក្នុងកិច្ចប្រជុំលើកទី៤ របស់គណៈកម្មការគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ....................................................................................... ៣៨
៣.៥. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាអធិបតីចូលរួមក្នុងកិច្ចប្រជុំទ្វេភាគីរវាង ធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម ............................................................ ៤០
៣.៦. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងវេទិកាសន្ទនាកម្រិតអ្នករៀបចំគោលនយោបាយក្នុងកម្មវិធីតាំងពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ឆ្នាំ២០២៣ ............ ៤១
៣.៧. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមក្នុងសន្និសីទអន្តរជាតិ MOEF-BOK-FSC-IMF ឆ្នាំ២០២៣ ក្រោមមូលបទ រូបិយប័ណ្ណឌីជីថល.................................................... ៤២
៣.៨. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម Cherdkiat Atthakor ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំព្រះរាជាណាចក្រកម្ពុជា................................ ៤៣
៣.៩. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំគណៈប្រតិភូចូលជួបប្រជុំពិភាក្សាការងារ ជាមួយអន្តរគណៈកម្មការរដ្ឋសភា ........................................................................ ៤៥
៣.១០. លោកជំទាវបណ្ឌិត ជា សិរី អនុញ្ញាតឱ្យគណៈប្រតិភូនៃធនាគារកណ្តាល ប្រទេសប៉ាពួញ៉ូហ្គីណេ កោះសូឡូម៉ូន និងប្រទេសវ៉ានូទូ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ .............. ៤៦
៣.១១. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបក្រុមបេសកកម្មមាត្រា IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ...................................................................................... ៤៧

៣.១២. លោកជំទាវបណ្ឌិត ជា សិរី អនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ជួបសម្តែងការគួរសម និងជម្រាបជូនអំពីវឌ្ឍនភាពនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ......... ៤៨

៣.១៣. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំកិច្ចប្រជុំ ស្តីពី "ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ "ក្រុម ង" នៃវេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន" ......... ៤៩

៣.១៤. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបពិភាក្សាការងារជាមួយប្រតិភូនៃក្រុមប្រឹក្សាធុរកិច្ចអឺរ៉ុប-អាស៊ាន និងសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា ......... ៥០

៣.១៥. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបលោក Davide Furceri ប្រធានក្រុមបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សម្រាប់កម្ពុជា ......... ៥២

៣.១៦. លោកជំទាវបណ្ឌិត ជា សិរី ជួបពិភាក្សាការងារជាមួយ លោក Ge Haijiao ប្រធានក្រុមប្រឹក្សាភិបាល ធនាគារចិន និងគណៈប្រតិភូ ......... ៥៣

៣.១៧. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំកិច្ចប្រជុំរវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ VISA ......... ៥៤

៣.១៨. លោកជំទាវបណ្ឌិត ជា សិរី និងថ្នាក់ដឹកនាំជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា អញ្ជើញដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធ រំលឹកខួបអនុស្សាវរីយ៍លើកទី៧០ នៃទិវាបុណ្យឯករាជ្យជាតិ... ៥៥

៣.១៩. លោកជំទាវបណ្ឌិត ជា សិរី ជួបពិភាក្សាជាមួយ ឯកឧត្តម Essa Kazim ទេសាភិបាលនៃមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិឌូបៃ ......... ៥៦

៣.២០. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំក្រុមយុវជនស្ម័គ្រចិត្តនៃធនាគារជាតិនៃកម្ពុជា សហការជាមួយក្រុមគ្រូពេទ្យជំនាញប្រទេសអាល្លឺម៉ង់ មូលនិធិចក្ខុខ្មែរ និងមូលនិធិរក្សាកុមារ ទទួលពិនិត្យ ព្យាបាល និងវះកាត់ភ្នែកឡើងបាយ និងកន្ទុយថ្លែន ដោយឥតគិតថ្លៃ ......... ៥៧


## ❁ ផ្នែកទី៤: តារាង (ភាសាខ្មែរនិងអង់គ្លេស)


៤.១. តារាងអត្រាប្តូរប្រាក់ប្រចាំខែ ......... ៥៨

៤.២. ប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ និងបម្រែបម្រួលប្រចាំខែ ......... ៦០

៤.៣. ឥណទានផ្តល់ដោយធនាគារទទួលប្រាក់បញ្ញើតាមប្រភេទជំនួញ និងបម្រែបម្រួលប្រចាំខែ. ៦១

៤.៤. ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងអង្គការមិនមែនរដ្ឋាភិបាល ......... ៦៣

៤.៥. ការផាត់ទាត់មូលប្បទានបត្រតាមរយៈសភាផាត់ទាត់ ......... ៦៤

៤.៦. ប្រព័ន្ធធនាគារកម្ពុជា ......... ៦៦

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងកម្មវិធីលៀងសាយភោជនប្រចាំឆ្នាំ២០២៣

ថ្ងៃចន្ទ ១៤រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ត្រូវនឹងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ

ᪿᪿᪿ✵ᪿᪿᪿ

**សូមគោរព៖**

**លោកជំទាវ ឯកឧត្តម អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយស ទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមក្នុងកម្មវិធីលៀងសាយភោជនធនាគារិកប្រចាំឆ្នាំ២០២៣។ ខ្ញុំសូមថ្លែងអរគុណជាអនេកចំពោះមនោសញ្ចេតនា សេចក្តីស្រឡាញ់ និងនឹករឭកចងចាំទុកជាអនុស្សាវរីយ៍ របស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាទាំងអស់។




ខ្ញុំពិតជាមានកិត្តិយសប្រកបដោយមោទនភាពណាស់ ដែលបានរួមសហការជាមួយ លោកជំទាវ ឯកឧត្តម អ្នកឧកញ៉ា លោក លោកស្រី ក្នុងការកសាងប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើនពីមួយដំណាក់កាលទៅមួយដំណាក់កាល ចាប់តាំងពីការធ្វើកំណែទម្រង់សេដ្ឋកិច្ចផែនការ មកជាសេដ្ឋកិច្ចទីផ្សារ ពីប្រព័ន្ធធនាគារមួយថ្នាក់ (Mono-Banking) ទៅជាប្រព័ន្ធធនាគារពីរថ្នាក់( Two-tier Banking) ពីការវិនិយោគដោយរដ្ឋ មកជាការវិនិយោគឯកជន ទាំងក្នុងស្រុកនិងបរទេស។ ការអភិវឌ្ឍរីកចម្រើននៃសេដ្ឋកិច្ចជាតិនិយាយជារួម និងប្រព័ន្ធធនាគារនៅកម្ពុជា និយាយដោយឡែក គឺអាស្រ័យដោយប្រទេសជាតិមានសុខសន្តិភាពពេញលេញ និងស្ថិរភាពនយោបាយក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អគ្គមគ្គុទេសក៍ដ៏ឆ្នើមនៃនយោបាយឈ្នះ-ឈ្នះ។






ដោយសារតែភាពអំណោយផលនេះហើយ ទើបធនាគារជាតិនៃកម្ពុជាអាចអនុវត្តមុខងារភារកិច្ចរបស់ខ្លួនបានល្អក្នុងការរក្សាស្ថិរភាពថ្លៃ ស្ថិរភាពហិរញ្ញវត្ថុ និងអភិវឌ្ឍប្រព័ន្ធទូទាត់ជាតិ។ ដូចដែល លោកជំទាវ ឯកឧត្តម អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា បានទស្សនានៅក្នុងខ្សែភាពយន្តខ្លី ក៏ដូចជាពិព័រណ៍របស់យើងរួចមកហើយថា ថ្មីៗកន្លងមកនេះ ធនាគារជាតិនៃកម្ពុជាទទួលបានពានរង្វាន់ជាច្រើន ទាំងក្នុងការដឹកនាំប្រព័ន្ធធនាគារ ការអភិវឌ្ឍប្រព័ន្ធទូទាត់ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ ក៏ដូចជាការបោះផ្សាយធនប័ត្រផ្ញើមប្រចាំឆ្នាំ។ ដូច្នេះ ខ្ញុំសូមចាត់ទុកថា ពានរង្វាន់ទាំងអស់នេះ ជាសមិទ្ធផលរួមរបស់យើងទាំងអស់គ្នា ដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងប្រកបដោយកិច្ចសហប្រតិបត្តិការល្អរវាង ធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។




ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងការកោតសរសើរ និងអំណរគុណចំពោះ ថ្នាក់ដឹកនាំគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ ក្នុងការអភិវឌ្ឍប្រព័ន្ធធនាគាររបស់យើងប្រកបដោយភាពរឹងមាំ ស្ថិរភាព និងបរិយាបន្នរយៈពេលកន្លងមក។

**លោកជំទាវ ឯកឧត្តម អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីមេត្រី!**

ការងាររបស់យើងមានការវិវឌ្ឍពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ដោយយើងបានអនុវត្តមុខងារភារកិច្ចរបស់យើងបានល្អ និងបានរួមគ្នាដោះស្រាយនូវបញ្ហាប្រឈមជាច្រើន ទាំងក្នុងវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨ និងវិបត្តិជំងឺកូវីដ-១៩ នាពេលថ្មីៗកន្លងទៅនេះ បានដោយជោគជ័យ។ ក្នុងន័យនេះ ប្រព័ន្ធធនាគាររបស់យើងមានភាពរឹងមាំល្អ និងអភិវឌ្ឍគួរឱ្យកត់សម្គាល់។ ទន្ទឹមនេះ ខ្ញុំសូមលើកសុភាសិតបារាំងមួយឃ្លាបានពោលថា "Enfants petits, petits soucis; enfants grandis, grands soucis." មានន័យថា ពេលកូននៅតូច ការបារម្ភនៅតិច ដល់ពេលកូនធំ ការបារម្ភក៏កាន់តែច្រើន ដូចគ្នានេះដែរ ប្រព័ន្ធធនាគាររបស់យើងមានការអភិវឌ្ឍរីកចម្រើនលូតលាស់ខ្លាំងនាពេលបច្ចុប្បន្ន ដែលទាមទារឱ្យបង្កើនការយកចិត្តទុកដាក់បន្ថែមលើការគ្រប់គ្រងហានិភ័យនានា ដែលអាចកើតឡើងជាយថាហេតុ និងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការល្អជាប្រពៃណីរវាងភាគីពាក់ព័ន្ធទាំងអស់ ។

ជាបទពិសោធន៍នៃការដឹកនាំធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ២៥ឆ្នាំកន្លងមក ខ្ញុំសូមវាយតម្លៃថា ប្រព័ន្ធធនាគារមួយអាចមានការអភិវឌ្ឍរីកចម្រើនប្រកបដោយស្ថិរភាពល្អទៅបាន គឺអាស្រ័យដោយប្រព័ន្ធធនាគារនោះ មានស្ថិរភាពរូបិយវត្ថុល្អ និងទទួលបានជំនឿទុកចិត្តពីសាធារណជន។ ដូចដែល លោក Per Jacobson អតីតនាយកគ្រប់គ្រងនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ធ្លាប់បានមានប្រសាសន៍ជម្រាបឧត្តមសេនីយ៍ Charles de Gaulle អតីតប្រធានាធិបតីបារាំងថា "សេដ្ឋកិច្ចបារាំងអាចស្តារ និងអភិវឌ្ឍក្នុងដំណាក់កាលក្រោយសង្គ្រាមលោក

លើកទី២បាន លុះត្រាតែបារាំងមានស្ថិរភាពរូបិយវត្ថុប្រកបដោយជំនឿទុកចិត្តដ៏រឹងមាំរបស់សាធារណជនបារាំង"។ ជាមួយគ្នានេះ ស្ថិរភាពរូបិយវត្ថុនេះក៏អាស្រ័យដោយកត្តាធនធានមនុស្ស ប្រកបដោយគុណវុឌ្ឍិ និងសាធារណជនយល់ដឹងច្បាស់អំពីដំណើរការរបស់ប្រព័ន្ធធនាគារ។ ក្នុងន័យនេះ ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ បន្តបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យធនាគារឱ្យកាន់តែមានសក្តានុពលបន្ថែមទៀត និងសូមបន្តចូលរួមក្នុងការងារអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន។ ការអភិវឌ្ឍធនធានមនុស្សនេះហើយ គឺជាការចងជាគំនិតរួមគ្នា ដូចសុភាសិតមួយបានពោលថា "La force lie un temps – l'idée enchaine pour toujours." មានន័យថា "កម្លាំងចងតែមួយពេល គំនិតចងជាដរាប" ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងការកោតសរសើរ និងអំណរគុណចំពោះ លោកជំទាវ ឯកឧត្តម អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញា ក្នុងការផ្តល់កិច្ចសហប្រតិបត្តិការល្អ ដែលជាកត្តាមិនអាចកាត់ផ្តាច់បាន នាំទៅរកការអភិវឌ្ឍប្រព័ន្ធធនាគារប្រកបដោយស្ថិរភាព និងបរិយាបន្ន។



ជាទីបញ្ចប់ ខ្ញុំសូមកោតសរសើរចំពោះ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលបានរៀបចំកម្មវិធីដែលជាប្រពៃណីនេះ។ ខ្ញុំសូមប្រសិទ្ធពរជ័យជូនចំពោះ លោកជំទាវ ឯកឧត្តម អ្នកឧកញ៉ា លោក លោកស្រី និងអ្នកនាងកញ្ញាទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន និងទទួលបានជ័យជំនះគ្រប់ភារកិច្ចក្នុងឱកាសឆ្នាំថ្មីឆ្នាំសកល២០២៤ ខាងមុខនេះ។

**សូមអរគុណ!**

# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយសៀវភៅ ស្តីពី
# "ដុល្លារូបនីយកម្មនៅកម្ពុជា៖ ទំនាក់ទំនងផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច"

ថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ

**សូមគោរព៖**

**- ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា ជាទីគោរព**

**- លោក TANINAI Ichitomo អនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុនប្រចាំកម្ពុជា**

**- លោក Kazumasa Sanui ប្រធានតំណាង JICA ប្រចាំកម្ពុជា**

**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

តាងនាមធនាគារជាតិនៃកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេកដែលបានចូលរួមក្នុងពិធីផ្សព្វផ្សាយសៀវភៅស្តីពី "ដុល្លារូបនីយកម្មនៅកម្ពុជា៖ ទំនាក់ទំនងផ្នែកគោលនយោបាយក្នុងការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច" ដែលទើបតែត្រូវបានបោះផ្សាយដោយរោងពុម្ពអន្តរជាតិ Rouledge នៃចក្រភពអង់គ្លេស កាលពីខែកញ្ញាកន្លងទៅ។ ខ្ញុំសូមស្វាគមន៍និងថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលឆ្លៀតឱកាសដ៏មានតម្លៃចូលរួមក្នុងពិធីនាពេលនេះ ទាំងការចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញលើបណ្តាញសង្គមរបស់ធនាគារជាតិនៃកម្ពុជា។





សៀវភៅនេះ គឺជាលទ្ធផលនៃកិច្ចសហការស្រាវជ្រាវរួមគ្នារវាងធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានស្រាវជ្រាវនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ចាប់តាំងពីឆ្នាំ២០១៣មកម្ល៉េះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ JICA ដែលបានរួមចំណែកក្នុងការស្រាវជ្រាវដ៏មានសារៈសំខាន់នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសចំពោះលោកសាស្ត្រាចារ្យ Hidenobu Okuda ដែលបានសហការរៀបចំ ដឹកនាំ និងកែសម្រួលខ្លឹមសារនៃអត្ថបទស្រាវជ្រាវ និងអ្នកនិពន្ធគ្រប់រូបដែលបានរួមចំណែកស្រាវជ្រាវលើផ្នែកនីមួយៗ ដែលបានធ្វើឱ្យសៀវភៅនេះ ក្លាយជាមូលដ្ឋានមួយសម្រាប់ការស្រាវជ្រាវថ្មីៗបន្ថែមទៀត កាន់តែស៊ីជម្រៅ និងជាធាតុចូលយ៉ាងសំខាន់ ក្នុងការរៀបចំតាក់តែងគោលនយោបាយនានា ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ដូចដែលលោក Kazumasa Sanui បានលើកឡើង។





**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ទាំងអស់ជាទីមេត្រី!**

ដុល្លារូបនីយកម្មបានកើតឡើង ក្នុងស្ថានភាពដែលជំនឿទុកចិត្តលើប្រាក់រៀលមានភាពទន់ខ្សោយក្រោយពីសង្គ្រាមស៊ីវិលជិត៣ទសវត្សរ៍ និងការហូរចូលយ៉ាងច្រើនសន្ធឹកសន្ធាប់នៃប្រាក់ដុល្លារអាមេរិក ក្នុងពេលរៀបចំការបោះឆ្នោតសកលលើកដំបូងនៅកម្ពុជា ដោយអាជ្ញាធរបណ្ដោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា ដែលហៅកាត់ថា UNTAC។ ជាការពិត ដុល្លារូបនីយកម្មបានរួមចំណែកជួយស្តារសេដ្ឋកិច្ច និងអមដំណើរនៃការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ជាមួយនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ។ ទោះយ៉ាងណា ដុល្លារូបនីយកម្មខ្ពស់បានដាក់កំហិតលើការអនុវត្តគោលនយោបាយរូបិយវត្ថុ។ នៅពេលដែលទំហំសេដ្ឋកិច្ចកម្ពុជាកើនឡើងកាន់តែធំ ការខ្វះលទ្ធភាពប្រើប្រាស់គោលនយោបាយរូបិយវត្ថុដោយពេញលេញ ក៏ធ្វើឱ្យសេដ្ឋកិច្ចកាន់តែងាយរងគ្រោះផងដែរ ហើយដែលបណ្ដាលឱ្យពឹងផ្អែកតែទៅលើគោលនយោបាយសារពើពន្ធ។ បច្ចុប្បន្ន ស្ទើរតែគ្រប់ប្រទេសទាំងអស់ លំហគោលនយោបាយសារពើពន្ធបានរួមតូចទៅៗ ដោយសារតែវិបត្តិផ្ទួនៗ ហើយប្រទេសនានាលើពិភពលោក បានពឹងផ្អែកកាន់តែច្រើនលើគោលនយោបាយរូបិយវត្ថុ ដើម្បីស្តារកំណើនសេដ្ឋកិច្ច។ ជាក់ស្តែង នៅក្នុងពេលវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៧-២០០៨ ធនាគារកណ្ដាលជាច្រើនបានកាត់បន្ថយអត្រាការប្រាក់គោលរហូតដល់ស្ទើរស្មើសូន្យ ដើម្បីជំរុញការវិនិយោគនិងការប្រើប្រាស់ ហើយក្នុងអំឡុងវិបត្តិកូវីដ-១៩ ធនាគារកណ្ដាលថែមទាំងបញ្ចេញ

សាច់ប្រាក់ដើម្បីជួយសេដ្ឋកិច្ចទៀតផង ដែលការអនុវត្តនេះត្រូវបានគេហៅថា គោលនយោបាយរូបិយវត្ថុវិសាមញ្ញ (Unconventional Monetary Policies)។ នៅក្រោយវិបត្តិកូវីដ-១៩ ធនាគារកណ្តាលភាគច្រើនបានបង្កើនអត្រាការប្រាក់គោលមកវិញ ដើម្បីប្រឆាំងនឹងការកើនឡើងនៃអតិផរណា។ លទ្ធភាពក្នុងការបង្កើនឬបន្ថយអត្រាការប្រាក់គោល ឬចាក់បញ្ចូលសន្ទនីយភាពទៅក្នុងសេដ្ឋកិច្ចបានប្រកបដោយប្រសិទ្ធភាព គឺអាស្រ័យលើការប្រើប្រាស់ពេញលេញ និងទូលំទូលាយនៃរូបិយវត្ថុជាតិ។




ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសស្ថិរភាពនយោបាយ បានផ្តល់ភាពអំណោយផលដល់ការពង្រឹងការប្រើប្រាស់ប្រាក់រៀលជាលំដាប់ ខណៈដែលសមាមាត្រនៃការប្រើប្រាស់ដុល្លារអាមេរិកនៅតែមានកម្រិតខ្ពស់។ បញ្ហានេះស្របទៅនឹងការរកឃើញនានារបស់អ្នកស្រាវជ្រាវ ដែលថា ពេលដែលដុល្លារូបនីយកម្មកើនដល់ចំណុចខ្ពស់មួយហើយ នឹងមិនងាយថយចុះវិញបានទេ (Hysterisis of Dollarization) គឺតម្រូវឱ្យមានការអនុវត្តគោលនយោបាយលើកទឹកចិត្តផងនិងគាំទ្រផង ដើម្បីកាត់បន្ថយកម្រិតដុល្លារូបនីយកម្ម។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជា បានពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលជាប្រចាំ និងបានអនុវត្តវិធានការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលផ្អែកលើយន្តការទីផ្សារ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០មក។ កត្តាទាំងនេះបានបង្កើនបរិមាណប្រាក់រៀលក្នុងចរាចរណ៍ពី ០,៨៥ ទ្រីលានរៀលកាលពី២០ឆ្នាំមុន ដល់១៤,៥ទ្រីលានរៀលនាពេលបច្ចុប្បន្ន ពោលគឺកើនឡើងប្រមាណ ១៦ ដង ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ច។ កំណើននេះជាជំហាននិងជាក្តីសង្ឃឹមដ៏សំខាន់ ដើម្បីឈានទៅបង្កើនការប្រើប្រាស់ប្រាក់រៀលបន្ថែមទៀត។

ខ្ញុំសូមគូសបញ្ជាក់ថា ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលមិនមែនជាការងារឬការទទួលខុសត្រូវផ្តាច់មុខរបស់ក្រសួង-ស្ថាប័ន ឬវិស័យណាមួយឡើយ តែគឺជាការងាររួមរបស់គ្រប់ក្រសួង-ស្ថាប័ន វិស័យឯកជន

និងប្រជាជនទូទៅទាំងអស់គ្នា ដែលទាមទារការសហការនិងគាំទ្របន្ថែមទៀតឱ្យកាន់តែសកម្មនិងមានសង្គតិភាព។ ក្នុងន័យនេះ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះ ការចូលរួមចំណែកពីគ្រប់ភាគីទាំងអស់ លើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ជាក់ស្តែង មានក្រុមហ៊ុន-សហគ្រាសកាន់តែច្រើន បានបើកប្រាក់បៀវត្សរ៍ដល់បុគ្គលិក-និយោជិតជាប្រាក់រៀល នៅតាមទីផ្សារទំនើបនានាក៏បានបិទស្លាកថ្លៃជារៀល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុភាគច្រើនក៏បានខិតខំបង្កើនឥណទាននិងប្រតិបត្តិការរបស់ខ្លួនជាប្រាក់រៀល។ ទាំងនេះគឺជាវឌ្ឍនភាពមួយដ៏សំខាន់ សម្រាប់ការអនុវត្តវិធានការបន្តបន្ទាប់ទៀតដោយពិលាស។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ទាំងអស់ជាទីមេត្រី!**

ខ្ញុំសូមចូលរួមអបអរសាទរចំពោះការបោះផ្សាយសៀវភៅស្តីពី "ដុល្លារូបនីយកម្មនៅកម្ពុជា" របស់យើងនាពេលនេះ។ ខ្ញុំសង្ឃឹមថាលទ្ធផលនៃការស្រាវជ្រាវនេះ នឹងផ្តល់បទពិសោធន៍ដ៏មានតម្លៃផងដែរដល់ប្រទេសកំពុងអភិវឌ្ឍន៍នានា ក្នុងការគ្រប់គ្រងបញ្ហាដុល្លារូបនីយកម្ម និងការប្រើប្រាស់គោលនយោបាយ ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចឱ្យបានកាន់តែប្រសើរ។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយផងដែរ ដែលការសម្ពោធសៀវភៅនេះ ធ្វើឡើងក្នុងឱកាសនៃខួប ៧០ឆ្នាំនៃចំណងការទូតមិត្តភាពកម្ពុជា-ជប៉ុន ដែលបង្ហាញកាន់តែច្បាស់ពីមិត្តភាពដ៏រឹងមាំនិងយូរអង្វែងរបស់កម្ពុជា-ជប៉ុន ព្រមទាំងការចូលរួមចំណែករបស់ប្រទេសជប៉ុន ក្នុងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះទីភ្នាក់ងារ JICA អ្នកស្រាវជ្រាវ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលចូលរួមផ្តល់កិច្ចសហការ ក៏ដូចជាការគាំទ្រ ដើម្បីឱ្យការស្រាវជ្រាវ និងរៀបចំតាក់តែងសៀវភៅរបស់យើងអាចបញ្ចប់ទៅបានប្រកបដោយជោគជ័យ និងមានគុណតម្លៃខ្ពស់ក្នុងមជ្ឈដ្ឋានស្រាវជ្រាវ។

**សូមអរគុណ!**

# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា
# ស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែនតាមឃ្យូអរកូដ"
# រវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុន AliPay Connect Pte. Ltd.

**Remarks by**

**H.E. Dr. Chea Serey, Governor of the National Bank of Cambodia**

**at the Signing Ceremony of the Memorandum of Understanding (MOU) on**

**"Cross Border QR Code Payment Cooperation"**

**Between the National Bank of Cambodia and Alipay Connect Pte. Ltd.**

Singapore, 15th November 2023




- **H.E. Rath Sovannorak, Deputy Governor of the National Bank of Cambodia**
- **Mrs. Yang Peng, President of Ant International**
- **Mr. Douglas Feagin, Senior Vice President of Ant Group and Head of Alipay Plus Cross-Border Mobile Payment Services of Ant International**
- **Distinguished Guests, Ladies and Gentlemen,**

**A Very Good Morning!**

Today I am delighted to attend the signing of this Memorandum of Understanding (MOU) between the National Bank of Cambodia (NBC) and Alipay Connect Pte. Ltd. set within the Singapore Fintech Festival 2023. This MOU signing marks another milestone in cross border payment. This cooperation will enable Alipay Plus and Bakong users to make secure, convenient cross-border QR code payments between each network.

I wish to emphasize the importance of payment systems in stimulating economic development by providing secure and efficient methods for people to conduct commercial activities and transfer money. Consequently, the NBC has made the development and modernization of payment systems a priority since 2012. To this end, the NBC has introduced several payment system infrastructures such as the National Clearing System (NCS), the FAST Payment System, the Online Banking System (OBS), the National Bank of Cambodia Platform (NBCP), Cambodia Shared Switch (CSS) and the Bakong System.




Cambodia has become a popular destination for Chinese and international tourists in recent years. With its rich history, stunning temples, and beautiful landscapes, Cambodia offers a unique and diverse travel experience. Visitors are drawn to the ancient ruins of Angkor Wat, the bustling markets of Phnom Penh, and the serene beaches of Sihanoukville. The warm hospitality of the Cambodian people and the delicious local cuisine also add to the appeal of this Southeast Asian country for Chinese and international tourists. As more direct flights and travel packages become available, the number of visiting Cambodia continues to grow, contributing to the country's tourism industry and economy. The benefit of QR code payment for tourist visits is the convenience and ease of use. Instead of carrying around cash or worrying about currency exchange, tourists can simply scan a QR code to make a payment at restaurants, shops, or attractions. This can save time and hassle,



allowing tourists to focus on enjoying their trip rather than dealing with financial logistics. Additionally, QR code payments are often secure and can help protect against theft or fraud, providing peace of mind for tourists during their visit.

For the economy, cross-border QR code payments can make a big difference in digital way and more convenience. Through the use of smartphones, travelers can easily use their mobile banking apps overseas to make payments in their own currency, giving visitors a smoother payment experience, which in turn leaves them with a positive outlook on the destination they are visiting. As communication barriers are removed, this further eases a traveler's ability to explore local businesses and give back to the local economy. Lastly and quite importantly, this simplicity in making payments provides merchants with a boost in revenue, helping to stimulate economic activity.

Today, Alipay Plus and the National Bank of Cambodia will sign a Memorandum of Understanding agreeing to jointly promote cross-border QR Code interoperability. Such cooperation will allow Alipay customers to use Alipay connect, including the Alipay App and mobile banking apps that are enabled for Alipay Plus, to scan KHQR codes to easily make payments. Cambodian residents will also be able to use the Bakong app and other mobile banking apps at Alipay QR Code accepting merchants in China and partner countries, thus optimizing the payment experience for cross border mobile payments in China and when traveling abroad.

I am confident that this collaboration will be beneficial for all parties involved.

To conclude, I would like to extend my wishes of continued success for all stakeholders as we embark on this journey of cooperation and achievement, and to all excellencies, distinguished guests, ladies and gentlemen present here today I would like to wish you continued good health and prosperity.

I am now ready to the signing ceremony.

**Thank you**

# សុន្ទរកថាបើក
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០២៣

**Opening Remarks by**

**H.E. Dr. Chea Serey, Governor of the National Bank of Cambodia**

**at CamTech Summit 2023**

Center for Banking Studies, Phnom Penh, 30th November 2023

**A Very Good Morning!**

**Excellencies, Distinguished Guests, Ladies and Gentlemen!**




It is my honor and great pleasure to welcome you to the CamTech Summit which is organized by the National Bank of Cambodia in collaboration with the Cambodia Association of Finance and Technology around the theme: "Forging Partnerships: Fostering Collaboration and Innovation for Digital Financial Services in Mekong and Beyond."

Your presence today is a testimony to the growing importance and dynamism of FinTech, as reflected by the increased adoption of new and innovative financial services throughout the banking sector. In partnership with and in support of the private sector, the National Bank of Cambodia has been at the forefront of this trend, leveraging new technologies to modernize payment systems by introducing a range of innovative solutions - the most prominent being our BAKONG backbone for payment systems to enhance interoperability, promote financial inclusion, and facilitate the ease of using the Cambodian Riel.

While the offer of digital financial services has kept growing over the years, especially since it enabled the financial sector to demonstrate its resilience throughout the Covid-19 pandemic, the FinTech industry has been given the opportunity to play a significant role in promoting financial inclusion, provided a number of challenges be addressed. Such challenges include, but are not limited to, digital literacy especially in the rural areas; cybersecurity risks; data privacy and data protection.

**Excellencies, Distinguished Guests, Ladies and Gentlemen!**

Promoting safety and efficiency in innovative products and services is the main objective of the National Bank of Cambodia in order to support the financial inclusion agenda of the Government and further encourage digital payments. To this end, the National Bank of Cambodia is committed to further support FinTech adoption, innovation and fair and transparent competition as reflected in its FinTech Development Roadmap (FDR) 2020- 2025 in alignment with the objectives of the Financial Sector Development Strategy (FSDS) 2016-20251 the National Financial Inclusion Strategy (NFIS) 2019-2025 and Digital Economy and Society Framework by the Royal Government of Cambodia (RGC).



Within these frameworks, the National Bank of Cambodia is looking forward to continuing cooperating closely with the private sector in order to fully harness the benefits of technology advancement in the service of consumers. The financial literacy campaigns jointly undertaken are one good example of what can be done together. I very much look forward to further dialogue and interaction between the National Bank of Cambodia and the private sector to address the challenges mentioned earlier through common reflection and joint actions for the promotion of a healthy, dynamic, fair, and inclusive environment.

**Excellencies, Distinguished Guests, Ladies and Gentlemen!**

The CamTech Summit is a unique opportunity to provide an integrated platform for policymakers, regulators, businesses and Tech players from various sectors to discuss the recent advancement of technologies both in Cambodia and globally, the opportunities and challenges they provide, and their growing importance in shaping the Cambodian economy in the digital era especially in the context of recovery from the Covid-19 pandemic. This platform will promote awareness, coordination, exchanging of views, knowledge and experience among all

stakeholders and enable policymakers and regulators to gather input for better design of appropriate policies and regulations to cope with fast-evolving technology, and especially prepare Cambodia for the transition towards a digital economy and moving from a middle income to an upper middle-income country. Together, let us take this opportunity to further enable a dynamic, secure, and inclusive growth of digital financial services.





I would like to express my appreciation to the Cambodia Association of Finance and Technology as well as all the sponsors for their cooperation, tremendous effort and support in organizing this important event. My sincere thanks also go to moderators and panellists from various sectors, development partners, and relevant organizations who have made time in their busy schedule to share their views, experiences, and best practices to better address opportunities and challenges of advanced technology in Cambodia.I would like to wish excellencies, distinguished guests, ladies and gentlemen good health, prosperity, and success in all endeavours.

**Thank you!**



# សុន្ទរកថាបើក
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី១០
# ស្តីពី "ហានិភ័យអាកាសធាតុ និងអន្តរកាលឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង"

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ត្រូវនឹងថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ




**សូមគោរព៖**

**- លោកស្រី Alissar Chaker តំណាងអង្គការ UNDP ប្រចាំកម្ពុជា!**

**- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

តាងនាមធនាគារជាតិនៃកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេកនិងស្វាគមន៍ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងនាងកញ្ញាទាំងអស់ ដែលកំពុងចូលរួមដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញនៃគណនី Facebook ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា នៅក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ២០២៣។ ឆ្នាំនេះគឺជាលើកទី១០ ហើយដែលធនាគារជាតិនៃកម្ពុជាបានបង្កើតឱ្យមានសន្និសីទម៉ាក្រូសេដ្ឋកិច្ចឡើង ក្នុងគោលបំណងរួមចំណែកក្នុងការស្រាវជ្រាវ ដែលជាការងារចាំបាច់សម្រាប់ការផ្តល់ជាធាតុចូលសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងនាមជាស្ថាបនិកនៃសន្និសីទម៉ាក្រូសេដ្ឋកិច្ចនេះ ខ្ញុំពិតជាមានមោទនភាពដែលនៅក្នុង១ទសវត្សរ៍កន្លងមកនេះ ប្រធានបទសំខាន់ៗជាច្រើនត្រូវបានលើកយកមកស្រាវជ្រាវជាអាទិ៍រួមមាន បញ្ហាស្ថិរភាពហិរញ្ញវត្ថុ បរិយាបន្នហិរញ្ញវត្ថុ មូលដ្ឋានកំណើនសេដ្ឋកិច្ច សហគ្រាសធុនតូច

និងមធ្យម ឱ្យដីថល ការស្តារសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩។ល។ ខ្ញុំសូមវាយតម្លៃខ្ពស់ថា លទ្ធផលនៃការស្រាវជ្រាវពីមួយឆ្នាំទៅមួយឆ្នាំកាន់តែមានគុណភាព ហើយអ្នកស្រាវជ្រាវដែលមានចំណាប់អារម្មណ៍បានចូលរួមកាន់តែច្រើន។

នៅឆ្នាំ២០២៣នេះ ធនាគារជាតិនៃកម្ពុជា បានជ្រើសរើសយកប្រធានបទពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងដំណើរឆ្ពោះទៅរកសេដ្ឋកិច្ចបៃតងរបស់កម្ពុជា។ ការសម្រេចកំណត់យកប្រធានបទនេះឡើង គឺដោយសារមជ្ឈដ្ឋានជាតិ តំបន់ និងអន្តរជាតិ បាននិងកំពុងផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំង ហើយបានជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធបញ្ជ្រាបបញ្ហានេះ ទៅក្នុងការអនុវត្តគោលនយោបាយនិងសកម្មភាពរបស់ខ្លួន។ ជាពិសេសទៅទៀតនោះ កម្ពុជាក៏បានដើរតួនាទីកាន់តែសកម្មក្នុងការរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងបានប្តេជ្ញាដាក់ចេញគោលនយោបាយឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង។





បច្ចុប្បន្ន សីតុណ្ហភាពពិភពលោកបានកើនឡើងប្រមាណ ១,២អង្សា ធៀបនឹងសម័យមុនបដិវត្តន៍ឧស្សាហកម្ម (១៨៥០-១៩០០) ហើយសីតុណ្ហភាពនឹងអាចកើនឡើងដល់ ២,៧អង្សា នៅត្រឹមឆ្នាំ២១០០ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងបន្ថែមទេនោះ។ ការកើនឡើងកម្តៅចាប់ពី ២អង្សា ត្រូវបានចាត់ទុកថាគឺជាចំណុចដែលមិនអាចស្តារវិញបាន ដូចជាការរលាយផ្ទាំងទឹកកកនៅតំបន់ប៉ូល ការបាត់បង់ប្រព័ន្ធជីវចម្រុះ និងការកកើតនៃមេរោគឆ្លងរាតត្បាតជាដើម។ ជាក់ស្តែង គ្រោះមហន្តរាយបានកើតចេញឡើងជាបន្តបន្ទាប់ ដោយសារការប្រែប្រួលអាកាសធាតុ ដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ដែលកើតមានកាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុន ព្រមទាំងបានបង្កជាវិបត្តិសុខភាព ស្បៀងអាហារ ការបាត់បង់អាយុជីវិត និងការខូចខាតហេដ្ឋារចនាសម្ព័ន្ធយ៉ាងដំណំ។ លើសពីនេះ ការប្រែប្រួលអាកាសធាតុមិនត្រឹមតែបង្កហានិភ័យជារូបវន្តប៉ុណ្ណោះទេ (physical risks) ថែមទាំងទៅលើសេដ្ឋកិច្ចនិងសង្គមទាំងមូល ដោយគ្មានព្រំដែន តាមរយៈវិស័យពាណិជ្ជកម្ម ការវិនិយោគ អតិផរណា អត្រាការប្រាក់ ភាពអត់ការងារធ្វើ រហូតដល់អស្ថិរភាពហិរញ្ញវត្ថុ សេដ្ឋកិច្ចនិងសង្គមទាំងមូល។

ដើម្បីឈានទៅកាត់បន្ថយការកើនឡើងកម្តៅឱ្យស្ថិតនៅទាបជាង ២អង្សា និងល្អបំផុតត្រឹម ១,៥អង្សា ស្របតាមគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ២០១៥ ពិភពលោកចាំបាច់ត្រូវកាត់បន្ថយការបញ្ចេញ




ឧស្ម័នផ្ទះកញ្ចក់ឱ្យបានយ៉ាងតិច ៤៥% ធៀបនឹងឆ្នាំ២០១៩ នៅត្រឹមឆ្នាំ២០៣០ និងឆ្ពោះទៅកាន់អព្យាក្រឹតកាបូន (net zero emission) ឱ្យបានត្រឹមឆ្នាំ២០៥០ ពោលត្រូវលុបបំបាត់ការបញ្ចេញឧស្ម័នកាបូន ឬរាល់ការបញ្ចេញឧស្ម័នកាបូនទៅក្នុងបរិយាកាស ត្រូវស្រូបយកមកវិញឱ្យស្មើសូន្យ។ ប៉ុន្តែ ការសម្រេចឱ្យបានមហិច្ឆតានេះ ត្រូវជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ដោយសារអព្យាក្រឹតកាបូន តម្រូវឱ្យមានការផ្លាស់ប្តូរដំណើរការនៃសេដ្ឋកិច្ចនិងសង្គម ដែលចាប់តាំងពីបដិវត្តន៍ឧស្សាហកម្មនៅក្នុងសតវត្សរ៍ទី១៩មក សេដ្ឋកិច្ចពិភពលោកបានពឹងផ្អែកយ៉ាងខ្លាំងទៅលើថាមពលហ្វូស៊ីលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វិទ្យាសាស្ត្រ និងបច្ចេកទេស។ ក្នុងន័យនេះ គេចាំបាច់ត្រូវការហិរញ្ញប្បទានសន្ធឹកសន្ធាប់ ដើម្បីវិនិយោគទៅលើការផលិតថាមពលស្អាត និងបច្ចេកវិទ្យា ដែលមិនបំភាយឧស្ម័នកាបូន ការអភិវឌ្ឍសេដ្ឋកិច្ចដោយគិតគូរដល់បរិស្ថាន និងរក្សាបាននូវគម្របព្រៃឈើដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការស្រូបយកឧស្ម័នកាបូន ទន្ទឹមនឹងការអភិវឌ្ឍជំនាញយុវជនស្របតាមការវិវត្តនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង ក៏ដូចជាស្មារតីភ្ញាក់រឭករបស់ប្រជាពលរដ្ឋ ក្នុងការផ្លាស់ប្តូរទម្លាប់ប្រើប្រាស់ថង់ប្លាស្ទិកនិងវត្ថុធាតុដើមផ្សេងទៀត ដែលមានលក្ខណៈបំពុលបរិស្ថានខ្លាំង។ល។ ម៉្យាងទៀត ឥទ្ធិពលនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ក៏នាំទៅរកការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលអាចភ្ជាប់ជាមួយនូវហានិភ័យនានា (transition risks)។ ហានិភ័យទាំងអស់នេះអាចបណ្តាលមកពីឥទ្ធិពលនៃការដាក់ចេញ និងអនុវត្តន៍នូវគោលនយោបាយ និងវិធានការក្នុងសកម្មភាពគាំទ្រដល់ការទប់ទល់បម្រែបម្រួលអាកាសធាតុ ហើយកិច្ចការទាំងនេះអាចមានភាពខុសប្លែកគ្នាទៅតាមតំបន់ និងប្រទេសនីមួយៗ ផ្អែកលើកម្រិត និងគោលនយោបាយអភិវឌ្ឍន៍រួមរបស់រដ្ឋាភិបាល។ ដូច្នេះ មុននឹងដាក់ចេញនូវវិធានការនានា ទាមទារឱ្យមានការសិក្សា និងពិភាក្សាឱ្យបានស៊ីជម្រៅ សំដៅគាំទ្រ និងបន្ស៊ីគ្នាឱ្យស្របជាមួយគោលដៅអភិវឌ្ឍជាតិ និងអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

កម្ពុជាជាប្រទេសមួយដែលបញ្ចេញឧស្ម័នកាបូនទាប ប៉ុន្តែជាប្រទេសមួយដែលងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសតាមរយៈវិស័យកសិកម្ម។ យោងតាមរបាយការណ៍ដែលទើបចេញផ្សាយកាលពីចុងខែតុលារបស់ធនាគារពិភពលោក កម្ពុជាកំពុងរងផលប៉ះពាល់ខ្លាំងពីការប្រែប្រួលអាកាសធាតុ

ដោយភាពរាំងស្ងួតនិងទឹកជំនន់បានកើតមានញឹកញាប់និងខ្លាំងជាងមុន ដែលក្នុងនោះផលស្រូវបានបាត់បង់ប្រមាណ ១០០លានដុល្លារអាមេរិកដោយសារគ្រោះរាំងស្ងួតបណ្តាលមកពីបាតុភូត El Nino កាលពីឆ្នាំ២០១៩ ខណៈដែលគ្រោះទឹកជំនន់នៅខែកញ្ញាឆ្នាំ២០២២ បានប៉ះពាល់ខេត្តចំនួន១៤ និងប្រជាពលរដ្ឋប្រមាណ ៨ម៉ឺន៥ពាន់គ្រួសារ។ គួររំលេចថា ជាទូទៅ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងវិស័យកសិកម្មដោយផ្ទាល់ និងវិស័យដទៃទៀតដោយប្រយោល។ ដោយម្ហូបអាហារតំណាងឱ្យជាង ៤៣% នៃកន្ត្រកទំនិញនិងសេវា ដែលក្រុមគ្រួសារនៅកម្ពុជាប្រើប្រាស់ជាប្រចាំ ដូចនេះ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅលើវិស័យកសិកម្ម អាចបង្កជាបញ្ហាសន្តិសុខស្បៀងនិងទំនិញឡើងថ្លៃ ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជារួម។ បញ្ហានេះក៏អាចនឹងរួមចំណែកបង្កើនវិសមភាពសង្គម និងធ្វើឱ្យក្រុមគ្រួសារនិងប្រជាពលរដ្ឋងាយរងគ្រោះធ្លាក់ចុះទៅក្រោមបន្ទាត់ក្រីក្រផងដែរ។

ប្រឈមនឹងបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់ និងគ្រប់គ្រងផលវិបាកកើតចេញពីការប្រែប្រួលអាកាសធាតុ ដោយបានកំណត់យកបញ្ហាថាមពល អាកាសធាតុ និងបរិស្ថានជារបៀបវារៈគោលនយោបាយដ៏សំខាន់មួយ ក្នុងចំណោមអាទិភាពគោលនយោបាយផ្សេងទៀត ដូចដែលបានឆ្លុះបញ្ចាំងក្នុង "ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣", "យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១" និង "យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨" សំដៅកាត់បន្ថយផលប៉ះពាល់ លើកកម្ពស់ការសម្របខ្លួន និងពង្រឹងភាពធន់នៃសេដ្ឋកិច្ចនិងសង្គមកម្ពុជា ទៅនឹងការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀបចំ និងគំនិតផ្តួចផ្តើមនៃ



ការជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព ក្នុងនោះរួមមាន៖ ១/-ការគាំទ្រការដាក់ចេញគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់ សមាគមធនាគារនៅកម្ពុជា ដើម្បីឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ចូលរួមអនុវត្ត ២/-ការរៀបចំក្របខណ្ឌសហប្រតិបត្តិការ រវាងធនាគារជាតិនៃកម្ពុជា ក្រសួងបរិស្ថាន និងសមាគមធនាគារនៅកម្ពុជា ដើម្បីចែករំលែកព័ត៌មាន និងបង្កើតឱ្យមានគំនិតផ្តួចផ្តើមនានាសម្រាប់សកម្មភាពទប់ទល់បម្រែបម្រួលអាកាសធាតុ និង ៣/-ការបណ្តុះបណ្តាលនិងកសាងសមត្ថភាពទៅលើហិរញ្ញវត្ថុប្រកបដោយចីរភាព និងការការពារហានិភ័យបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជា ក៏បានចូលរួមក្នុងក្របខណ្ឌអន្តរជាតិតាមរយៈគំនិតផ្តួចផ្តើម និងកិច្ចពិភាក្សា ជាមួយស្ថាប័នមួយចំនួនដូចជា បណ្តាញធនាគារកណ្តាលនិងអាជ្ញាធរត្រួតពិនិត្យសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុបៃតង (Network of Central Banks and Supervisors for Greening the Financial System-NFGS) ក្រុមការងារបរិយាបន្នហិរញ្ញវត្ថុបៃតង (Inclusive Green Finance Working Group-IGFWG) គម្រោងភាពជាដៃគូសម្រាប់សកម្មភាពសេដ្ឋកិច្ចបៃតងរបស់អង្គការសហប្រជាជាតិ (UN Partnership for Action on Green Economy – PAGE) និង ក្រុមការងារអាស៊ានលើកិច្ចការបណ្តាញធនាគារនិងហិរញ្ញវត្ថុប្រកបដោយចីរភាព (ASEAN Taskforce on Sustainable Finance and Sustainable Banking Network)។ ធនាគារជាតិនៃកម្ពុជា ក៏បានសហការជាមួយអង្គការជាច្រើនដូចជា UNESCAP, សម្ព័ន្ធសម្រាប់បរិយាបន្នហិរញ្ញវត្ថុ (AFI) សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ក្នុងកិច្ចការពង្រឹងការចូលរួមផ្តល់ហិរញ្ញប្បទានបៃតង ព្រមទាំងបានវិនិយោគទុនបម្រុងអន្តរជាតិមួយផ្នែកលើសញ្ញាបណ្ណបៃតង និងបានក្លាយជាសមាជិកនៃគណៈកម្មការពិគ្រោះយោបល់ សម្រាប់មូលនិធិបៃតងក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងឆ្នាំ២០២២ ផងដែរ។

ទិសដៅបន្ត ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តគំនិតផ្តួចផ្តើមសំខាន់ៗបន្ថែមទៀតក្នុងគោលដៅ បង្កើតឱ្យមានយន្តការគាំទ្រ និងប្រព័ន្ធអេកូឡូស៊ីចាំបាច់ ដើម្បីជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព និងសកម្មភាពជាសារវន្តក្នុងការពារហានិភ័យបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ។ កិច្ចការទាំងនោះរួមមាន៖ ១/-ការបង្កើតផែនទីមគ្គុទ្ទេសក៍ហិរញ្ញវត្ថុប្រកបដោយចីរភាព (Sustainable Finance Roadmaps) ២/-ការបង្កើតប្រព័ន្ធវដ្តករសាស្ត្រសម្រាប់ហិញ្ញវត្ថុប្រកបដោយចីរភាព (Sustainable Finance Taxonomy) ៣/-ការរៀបចំយន្តការរាយការណ៍ស្តីពី ហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីតម្លាភាព និងការទទួលខុសត្រូវ (Reporting and Disclosure Framework) ៤/-ការកសាងសមត្ថភាព និងចំណេះដឹង ដល់វិស័យធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធ (Capacity Building and Awareness Raising) និង ៥/-ការពង្រឹងក្របខណ្ឌវាយតម្លៃ និងការពារហានិភ័យបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (Climate Risks Analysis and Mitigation) ជាដើម។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ទោះយ៉ាងណា ការរួមបញ្ចូលគោលនយោបាយឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនិងលើកកម្ពស់សេដ្ឋកិច្ចបៃតងទៅក្នុងចក្ខុវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ទាមទារនូវការប្តេជ្ញាខ្ពស់ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ និងចាប់ពីពេលនេះតទៅ ពីព្រោះដើម្បីសម្រេចបានចក្ខុវិស័យឆ្នាំ២០៥០ ក្នុងការសម្រេចបានអព្យាក្រឹតកាបូននិងការប្រែក្លាយកម្ពុជាទៅជាប្រទេសអភិវឌ្ឍន៍ដែលមានភាពធន់ តម្រូវឱ្យមានការតម្រង់ទិសគោលនយោបាយ និងការអនុវត្តផែនការសកម្មភាពជាប់ជាប្រចាំ។

ខ្ញុំជឿថា សន្និសីទម៉ាក្រូសេដ្ឋកិច្ចនាថ្ងៃនេះ នឹងជម្រាបជូនពីលទ្ធភាពស្រាវជ្រាវរបស់អ្នកស្រាវជ្រាវយើងដែលមកពីក្រសួងបរិស្ថាន ធនាគារជាតិនៃកម្ពុជា មជ្ឈដ្ឋានឧត្តមសិក្សា និងដៃគូអភិវឌ្ឍន៍ ដែលបានធ្វើការស្រាវជ្រាវជុំវិញហានិភ័យនៃការប្រែប្រួលអាកាសធាតុនិងដំណើរឆ្ពោះទៅសេដ្ឋកិច្ចបៃតង។ បន្ថែមលើនេះ យើងក៏មានវាគ្មិនគន្លឹះ អ្នកជំនាញ និងតំណាងមកពីក្រសួងស្ថាប័នពាក់ព័ន្ធទាំងសាធារណៈនិងឯកជន ចូលរួមផ្តល់កិច្ចពិភាក្សា ចែករំលែកចំណេះដឹងទៅលើបញ្ហានេះផងដែរ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះអង្គការ UNDP ដែលបានចូលរួមសហការរៀបចំសន្និសីទនេះឡើង និងសូមថ្លែងអំណរគុណចំពោះវាគ្មិនគន្លឹះ វាគ្មិនពិភាក្សា និងអ្នកស្រាវជ្រាវរបស់យើងទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមចំណែកក្នុងការធ្វើឱ្យការស្រាវជ្រាវ ក៏ដូចជាការពិភាក្សា នៅក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចនាថ្ងៃនេះ។ ខ្ញុំក៏សូមគូសបញ្ជាក់ផងដែរថា ការស្រាវជ្រាវនៅកម្ពុជានៅខ្វះខាតជាច្រើន ទាំងការចូលរួមរបស់អ្នកស្រាវជ្រាវ ទាំងគុណភាពនៃការស្រាវជ្រាវ ដែលទាមទារមានកិច្ចខិតខំពង្រឹងការស្រាវជ្រាវបន្ថែមទៀត ជាពិសេសការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការលើកកម្ពស់ការចូលរួមការស្រាវជ្រាវនិងការបណ្តុះបណ្តាលលើការស្រាវជ្រាវ។ *[លោក Neil Armstrong អាកាសយានិករបស់សហរដ្ឋអាមេរិកទី១ដែលបានទៅដល់ភពព្រះច័ន្ទបានលើកឡើងថា "ការសិក្សាស្រាវជ្រាវគឺជាដំណើរការនៃការបង្កើនចំណេះដឹង"។ ចំណេះដឹងថ្មីៗនេះហើយដែលនឹងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឱ្យមានការរីកចម្រើនប្រកបដោយនិរន្តរភាព។]*

ខ្ញុំសូមជូនពរឱ្យសន្និសីទរបស់យើងដំណើរការដោយជោគជ័យ និងសូមប្រកាសបើកសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី១០ ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

# សុន្ទរកថា

## លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀង ជាមួយគណៈកម្មការសេដ្ឋកិច្ចនិងសង្គម ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ

**Remarks by**

**H.E. Dr. Chea Serey, Governor of the National Bank of Cambodia**

**at Memorandum of Agreement signing ceremony with UNESCAP**

Phnom Penh, 8th December 2023

**Good morning**

**- Mr. Jo Scheuer, UN Resident Coordinator in Cambodia**

**- Ms. Alissar Chaker, Resident Representative of UNDP Cambodia**

**- Ms. Subathirai Sivakumaran, Chief of Financing for Development, UNESCAP**

**- Distinguished Guests, Excellencies, Ladies and Gentlemen,**



It is my great pleasure and honor to warmly welcome you to the signing ceremony of the Memorandum of Agreement between the United Nations Economic and Social Commission for Asia and the Pacific and the National Bank of Cambodia.

As we recall, the NBC has had a long history of productive collaboration with UNESCAP, particularly when it comes to financial inclusion and literacy, especially the campaign called Let's Talk Money: Little by Little, among others, that aims to reduce over-indebtedness among low-income households and vulnerable communities.

Today, we reached a new cooperative milestone, the MoA signing. This MoA will further strengthen the close cooperation between the ESCAP and the NBC, especially in the area of promoting sustainable finance in Cambodia, which is aligned with the Pentagonal Strategy- Phase I of the government.

In our recent cooperation between the NBC and UNESCAP, an inception report was made to take stock of the current sustainable finance environment and market in Cambodia. Among the recommendations in the report, a National Sustainable Finance roadmap should be created, and the MoA marks the start of this new initiative.

Through the MoA, we will be developing a roadmap that is inclusive, integrated, multi-stakeholders, strategic approach to accelerate the development of a sustainable finance system. This roadmap will include a clear plan for aggregating finance needs, gaps, sources, and options in line with the national sustainable development climate targets. It will also show prospective projects and investment pipelines that are eligible for financing.

I am confident that with the collaboration and support from UNESCAP, we will be able to provide a proper legal framework, supportive infrastructure, incentives, and clear guidelines to ensure that the financial sector can better fulfil its role as an effective financial intermediary between private capital and sustainable activities in Cambodia. Additionally, I am optimistic that the plan we are currently formulating is not limited to the banking and financial industry alone. It is designed to provide a framework that enables all relevant stakeholders to actively participate and reap the benefits of its execution.

On this note, I would like to take this chance to request cooperation and collaboration from various entities such as ministries, regulators, public institutions, financial organizations, private sectors, and development partners to collectively combat climate change.

Before concluding, I would like to extend my gratitude to UNESCAP for your continuous supports to the National Bank of Cambodia, particularly on technical assistance and capacity building to our staff.

I look forward to the successful implementation of our MoA and further deepen our cooperation.

Finally, I would like to wish you all good health, happiness and success in your endeavors.

**Thank You!**



# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងកម្មវិធីកិច្ចប្រជុំកំពូលធុរកិច្ចអាស៊ាន-ជប៉ុន ឆ្នាំ២០២៣

**Remarks by**

**H.E. Dr. Chea Serey, Governor of the National Bank of Cambodia**

**on "Building ASEAN-Japan Community Contributing to the World"**

**at the ASEAN-JAPAN Young Business Leaders' Summit 2023**

Karuizawa, Japan, $14^{th}$ December 2023

- **Mr. Ishiguro Norihiko, Chairman and CEO of the Japan External Trade Organization (JETRO)**
- **Mr. Tetsuya Watanabe, President of the Economic Research Institute for ASEAN and East Asia (ERIA)**
- **Esteemed Chairs of the ASEAN-JAPAN Young Business Leaders' Summit**
- **Excellencies, Distinguished Guests, Ladies and Gentlemen,**

**Good morning!**



I stand before you today with a deep sense of gratitude for the honor of being invited to this remarkable summit. It is with great enthusiasm that I embrace this opportunity to share my insights on a topic of paramount significance – "Building ASEAN-Japan Community Contributing to the World." As we commemorate the golden jubilee of ASEAN and Japan's enduring friendship and cooperation, I am truly humbled to be part of this significant conversation.

It is crucial to acknowledge the pivotal role that Japan plays within ASEAN. As many of you are aware, Japan stands as the fourth largest trading partner and the second largest source of foreign direct investment (FDI) to ASEAN. Indeed, in 2022, the total trade volume between Japan and ASEAN surpassed an impressive USD 268 billion. Equally noteworthy is the substantial FDI from Japan to ASEAN, amounting to a staggering USD 26.7 billion. The figures not only highlight the significance of the cooperation between ASEAN and Japan, but also

emphasize the necessity to further strengthen and enhance this alliance. This becomes particularly important considering the current global landscape, where there is a growing risk of global trade fragmentation due to strategic competition among major countries.

During the 25th ASEAN-Japan Summit in November 2022 in Phnom Penh, Cambodia, our leaders reaffirmed their commitment to further strengthening the ASEAN-Japan partnership and cooperation through existing cooperation frameworks, such as the "Renewed ASEAN – Japan 10-year Strategic Economic Cooperation Roadmap 2016 – 2025", and the "ASEAN – Japan Economic Resilience Action Plan". These collaborations have resulted in a significant development in the region over the last decade, including a rapid and comprehensive recovery from the COVID-19 pandemic. In fact, according to the ASEAN+3 Macroeconomic Research Office's (AMRO) projections, ASEAN is expected to achieve a commendable growth rate of 4.4% this year and 5% next year. This resilient growth is particularly noteworthy and stands as a testament to the collective resilience and determination of our nations, even amidst the prevailing global economic slowdown and ongoing adversities.

In the face of common challenges, both ASEAN and Japan find themselves at a critical juncture. Climate change and the complexities of an ageing society loom large on our collective horizon. Many ASEAN countries are also grappling with technological disruptions that require careful management to mitigate associated risks. To address these issues, we have jointly prepared the "ASEAN-Japan Economic Co-Creation Vision" and "Future Design and Action Plan of an Innovative Sustainable ASEAN-Japan Economic Partnership", which outline our shared goals of achieving sustainable development, promoting cross-border innovation, strengthening connectivity, and developing human capital, among other major commitments. By embracing this vision and action plan, ASEAN stands to benefit immensely from Japan's invaluable expertise in climate change and natural disaster management, as well as its prowess in enhancing cross-border connectivity, driving innovation, and addressing social challenges.

In order to bring our vision to life, it is crucial to promote joint efforts between the public and private sectors in both ASEAN and Japan. As we strive for a seamless transition into greener economies, we must recognize that the mobilization of substantial funds cannot be achieved by the public sector alone. It is imperative that we garner the support and active participation of the private sector. Additionally, harmonizing the definition of what constitutes sustainable financing as well as standards and rules is critical for successful collaboration among all stakeholders, transcending borders and boundaries. The same principle applies to the promotion of innovation. The private sector, with its financial resources and expertise, serves as the driving

force behind innovation. However, it is equally crucial for the public sector to create a supportive and regulatory framework that nurtures and facilitates this innovation.

**Excellencies, Distinguished Guests, Ladies and Gentlemen,**

As a citizen of Cambodia, it is important for me to acknowledge and express my appreciation towards the Government of Japan and the Japanese people for their significant contributions to Cambodia's economic recovery and societal progress over the last few decades. This year (2023) marks the 70th anniversary of diplomatic relations between Japan and Cambodia, which commenced in 1953. Following the Khmer Rouge regime, Japan's commitment to our nation's well-being has been unwavering, playing a pivotal role in assisting Cambodia's peace-building endeavors and driving economic development. Their assistance encompassed various aspects, including the construction of vital infrastructure, the development of human capital, and the preservation of our cherished cultural heritage sites. Since 1992, Japan has been the leading bilateral donor, implementing numerous social programs aimed at alleviating poverty in Cambodia. Additionally, Japan has been a significant partner in terms of trade and investment, being the fourth largest buyer of Cambodian goods in 2022 and the fourth major investor as of Q3 2023.

Moving forward, in order to align with the 2030 Agenda for Sustainable Development, Cambodia still requires substantial support from other countries, and Japan's keen interest in supporting Cambodia has always been appreciated. Alongside Cambodia's goal of achieving upper-middle-income status by 2030, we must address the lasting consequences of the pandemic and external challenges. Despite these obstacles, we remain optimistic and committed to achieving our goals. Cambodia needs more investments, particularly quality investments that foster connections with our Micro-, Small- and Medium-sized Enterprises (MSMEs), which represent more than 99% of our total enterprises. These MSMEs encounter challenges such as



limited digital adoption, innovation, and financial resources, which hinder their competitiveness compared to their regional counterparts. As such, Cambodian leaders, myself included, are looking forward to engaging in dialogues with Japanese investors and companies to explore investment and business opportunities in Cambodia.

The success of the National Bank of Cambodia's Bakong digital payment system demonstrates the positive outcome that can result from a strong collaboration between a public authority and a private company, like SORAMITSU, a Japanese technology company. Bakong has gained significant recognition both domestically and internationally for its substantial contribution to enhancing financial inclusion, promoting interconnectivity, and ensuring interoperability of digital payment systems within the kingdom and across borders. This has enabled Cambodia to leapfrog many stages of development and become one of the leading countries in electronic payment systems among its peers.

**Excellencies, Distinguished Guests, Ladies and Gentlemen,**

As I conclude my remarks today, I am reminded of the profound impact that partnerships can have in navigating the complexities and uncertainties of our world. The remarkable success of the National Bank of Cambodia's Bakong serves as a good example of what can be achieved through close collaboration with the private sector and relevant stakeholders. It underscores the vital importance of fostering a culture of dialogue and partnership between the public and private sectors, both locally and internationally, as we strive for sustainable and inclusive development.

Together, as leaders of ASEAN and Japan, we have the opportunity to leverage our distinct and complementary strengths. Through platforms like this summit, we can forge even stronger bonds and work towards achieving greater successes for our region, our countries, and most importantly, our people.

Let us carry the spirit of collaboration and partnership forward, as we continue to build an ASEAN-Japan community that contributes to the world.

**Thank you for your kind attention!**

# សុន្ទរកថា

## លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងកម្មវិធីប្រកាសដាក់ឱ្យដំណើរការប្រតិបត្តិការទូទាត់ឆ្លងដែន តាមយូអរកូដ (QR Code) ជាផ្លូវការរវាងប្រព័ន្ធទូទាត់បាគង របស់ធនាគារជាតិនៃកម្ពុជា និងបណ្តាញទូទាត់របស់ក្រុមហ៊ុន UPI

**Remarks by**

**H.E. Dr. Chea Serey, Governor of the National Bank of Cambodia**

**at the Official Launching Ceremony of Cross-Border QR Code Payment**

**between the National Bank of Cambodia and UnionPay International**

Phnom Penh, 22nd December 2023



- **H.E. WANG Wentian, Ambassador Extraordinary and Plenipotentiary of the People's Republic of China to the Kingdom of Cambodia,**
- **H.E. TOP Sopheak, Secretary of State and Spokesperson of the Ministry of Tourism,**
- **Excellencies, Distinguished Guests, Ladies and Gentlemen!**

**A Very Good Afternoon!**

Today, I have the great honors and pleasure to participate in this official launching ceremony of Cross-Border QR Code Payment between the National Bank of Cambodia and

UnionPay International, which institutionalizes an important partnership between the National Bank of Cambodia and UnionPay International.

Taking this opportunity, I would like to emphasize that promoting safety and efficiency in innovative products and services is a main objective of the National Bank of Cambodia to support the financial inclusion agenda of the Royal Government of Cambodia and further encourage digital payments. To this end, the National Bank of Cambodia is committed to further enhancing the safety, security, and convenience of cross-border payments.

As a regulator and overseer, the National Bank of Cambodia has formulated regulations, policy frameworks, and rules and procedures to manage, supervise and support payment systems. As a facilitator, it has enabled cross-border payment linkages, and is currently undertaking cross-border payment projects with partner and regional countries. At present, the National Bank of Cambodia has successfully launched cross-border QR code payments with Thailand, Lao PDR, and Vietnam.

Given the opportunity to increase global payment system connectivity, the National Bank of Cambodia has initiated cooperation with UnionPay International to explore the immense potential of cross-border QR code payments for both individual users and merchants, as well as its benefits to the real economy. On July 10th, 2023, both parties signed a Memorandum of Understanding, agreeing to jointly promote cross-border QR code interoperability between their networks. After the MOU was signed, the two parties conducted a feasibility study to understand the policy, technical and operational requirements for this project. Through hard work and good cooperation, the project has now been successfully implemented. From today onwards, visiting UnionPay cardholders will be able to use their



UnionPay-enabled wallets, such as the UnionPay app and commercial bank apps that are enabled for UnionPay QR Code payment, to scan KHQR codes to complete payment transactions at approximately 1.8 million merchants in Cambodia. Additionally, by early 2024, Cambodian residents will be enabled to use their Bakong wallet to make payments at UnionPay QR code accepting merchants in China and globally, thereby optimizing the mobile payment experience during international travels.

**Excellencies, Distinguished Guests, Ladies and Gentlemen!**

I strongly believe that the introduction of cross-border QR code payments between the National Bank of Cambodia's Bakong and UnionPay International will elevate the level of financial cooperation between both institutions by leveraging the technology to benefit users in both countries, and globally. In addition, this collaboration will substantially contribute to the promotion of trade, tourism activities and financial inclusion.







Therefore, I am pleased to declare the official launch of Cross-Border QR Code Payment between the National Bank of Cambodia and UnionPay International!

I would like to conclude my remarks by wishing your excellencies, distinguished guests, ladies and gentlemen, good health and continued success – and with the upcoming year-end, a Happy New Year 2024!

**Thank you!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ.១៤-០២៣-០៥៥ ព្រ.ក.ស.ក.ស.ខ

ថ្ងៃ ចន្ទ ៦ កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ ស្តីពី ការទូទាត់ឆ្លងដែនតាមឃ្យូអរកូដ រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន

នៅថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងឯកឧត្តម SAITO Ken រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន បានអញ្ជើញចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ ស្តីពី ការទូទាត់ឆ្លងដែនតាមឃ្យូអរកូដ (Unified QR Code-Based Payment) ។

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការនេះ រៀបចំឡើងក្រោមសហអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **KISHIDA Fumio** នាយករដ្ឋមន្ត្រី នៃប្រទេសជប៉ុន នៅក្នុងកិច្ចប្រជុំកំពូលកម្ពុជា-ជប៉ុន ដែលបានប្រព្រឹត្តទៅនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣។

អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការនេះ រៀបចំឡើងក្នុងគោលបំណងកំណត់ក្របខណ្ឌជាក់លាក់សម្រាប់កិច្ចសហប្រតិបត្តិការលើកកម្ពស់សកម្មភាពប្រើប្រាស់ប្រព័ន្ធទូទាត់ឆ្លងដែនតាមឃ្យូអរកូដ (QR Code) ដ៏ងាយស្រួល មានសុវត្ថិភាព និងប្រសិទ្ធភាព។ ក្របខណ្ឌកិច្ចសហប្រតិបត្តិការនេះក៏នឹងជួយបង្កើនចរាចររូបិយវត្ថុជាតិ ព្រមទាំងជំរុញវិស័យទេសចរណ៍រវាងប្រទេសទាំងពីរឱ្យកាន់តែមានសក្តានុពលថែមទៀតផងដែរ។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA

ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

International Finance Corporation
WORLD BANK GROUP
*Creating Markets, Creating Opportunities*

*ថ្ងៃអង្គារ ៧កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧*
*រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣*

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ធនាគារជាតិនៃកម្ពុជា ចាប់ដៃគូជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដើម្បីជំរុញហិរញ្ញប្បទានបៃតង គាំទ្រសកម្មភាពអាកាសធាតុ

ដើម្បីចូលរួមចំណែកក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងបង្កើតបរិយាកាសអំណោយផលសម្រាប់ទាក់ទាញហិរញ្ញប្បទានបៃតង ធនាគារជាតិនៃកម្ពុជា (NBC) និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការ ដើម្បីជំរុញការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងបៃតងក្នុងគោលដៅគាំទ្រការផ្លាស់ប្តូរសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចបៃតង។

បច្ចុប្បន្ន ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ ៦២ ក្នុងចំណោមប្រទេសចំនួន ១៩១ ផ្អែកលើសន្ទស្សន៍នៃការវាយតម្លៃហានិភ័យជាសកលពីប្រភពចំហ លើកត្តាមនុស្សធម៌ និងគ្រោះមហន្តរាយ។ ប្រទេសកម្ពុជាប្រឈមខ្លាំងនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលកាន់តែមានការវិវត្តមិនល្អក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ ប្រសិនបើគ្មានវិធានការបន្សាំ និងការកាត់បន្ថយឱ្យបានត្រឹមត្រូវទេ និងទាន់ពេលវេលា ការប្រែប្រួលអាកាសធាតុអាចបណ្តាលឱ្យសេដ្ឋកិច្ចកម្ពុជាថយចុះប្រមាណ ៩% នៃផលិតផលក្នុងស្រុកសរុប (GDP) ត្រឹមឆ្នាំ២០៥០ ខណៈដែលអត្រាភាពក្រីក្រអាចកើនរហូតដល់ ៦% ត្រឹមឆ្នាំ២០៤០ នេះបើយោងតាមរបាយការណ៍របស់ធនាគារពិភពលោក និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ស្តីពីស្ថានភាពអាកាសធាតុនិងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា/ Country Climate and Development Report (CCDR) ដែលទើបចេញផ្សាយកាលពីពេលថ្មីៗកន្លងទៅនេះ។ របាយការណ៍នេះបានប៉ាន់ប្រមាណថា ប្រទេសកម្ពុជាត្រូវការការវិនិយោគបន្ថែមប្រមាណ ៣៦ ប៊ីលានដុល្លារអាមេរិកពីវិស័យសាធារណៈ និងវិស័យឯកជន សម្រាប់រយៈពេល ៣ទសវត្សរ៍ខាងមុខ ដើម្បីសម្រេចបានតាមគោលដៅអាកាសធាតុអព្យាក្រឹតកាបូននៅមុនឆ្នាំ២០៥០។

ឯកឧត្តម យឹម លាត ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា មានប្រសាសន៍ថា "វិស័យហិរញ្ញវត្ថុដើរតួនាទីស្នូលយ៉ាងសំខាន់ ក្នុងការជំរុញការបញ្ចេញដើមទុនសម្រាប់គម្រោងដែលមិនមានផលប៉ះពាល់អាកាសធាតុ ប៉ុន្តែការណ៍នេះតម្រូវឱ្យមានគោលនយោបាយសមស្រប និងការបង្កើតបរិយាកាសអំណោយផល"។ ឯកឧត្តមបានបន្ថែមថា "ធនាគារជាតិនៃកម្ពុជាប្តេជ្ញារៀបចំអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុបៃតងមួយដ៏រឹងមាំ ដើម្បីបង្កើតប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុដែលគាំទ្រការបញ្ចូន និងជំរុញការវិនិយោគលើគម្រោងបៃតងនៅក្នុងប្រទេសកម្ពុជា ដើម្បីគាំទ្រដល់មហិច្ឆតាពាក់ពន្ធ័នឹងអាកាសធាតុរបស់រដ្ឋាភិបាល ដូចមានចែងនៅក្នុងរបាយការណ៍ការចូលរួមចំណែក

របស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស”។

បច្ចុប្បន្ន មានកត្តាមួយចំនួនដែលរារាំងសក្តានុពលហិរញ្ញប្បទានបៃតងរបស់កម្ពុជា ដូចជាកង្វះការណែនាំអំពីចារឹកលក្ខណៈនៃហិរញ្ញប្បទានបៃតង និងកង្វះខាតគោលនយោបាយបៃតងដើម្បីជំរុញការច្នៃប្រឌិត ការណែនាំ និងការអនុវត្តហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។

កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ តាមរយៈការបង្កើតប្រព័ន្ធវត្តិករសាស្ត្រហិរញ្ញវត្ថុជាតិ (National Taxonomy) ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ដែលនឹងជួយកំណត់ទ្រព្យសកម្មដែលមានចារឹកលក្ខណៈជាការវិនិយោគបៃតង។ លើសពីនេះ កិច្ចសហប្រតិបត្តិការនេះនឹងជួយបង្កើនសមត្ថភាពស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងរៀបចំគោលការណ៍ណែនាំពាក់ព័ន្ធ ដូចជាការរាយការណ៍និងស្តង់ដារនៃការបង្ហាញព័ត៌មានទាក់ទងនឹងការផ្តល់ឥណទានបៃតង និងគម្រោងហិរញ្ញប្បទាននានាពាក់ព័ន្ធនឹងហានិភ័យបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។

លោក ASAD YAQUB ប្រធានសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិប្រចាំនៅកម្ពុជា បានលើកឡើងថា “កិច្ចព្រមព្រៀងនេះ នឹងចូលរួមគាំទ្រដល់មហិច្ឆតាពាក់ព័ន្ធនឹងអាកាសធាតុរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងជំរុញទីផ្សារហិរញ្ញប្បទានបៃតងមួយដ៏រឹងមាំ។ ក្នុងនាមជាអ្នកនាំមុខផ្នែកហិរញ្ញប្បទានបៃតងសកល សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិមានជំហរពិសេសក្នុងការជួយប្រជាជាតិកម្ពុជា ក្នុងការកៀរគរហិរញ្ញប្បទានសម្រាប់សកម្មភាពទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីរួមចំណែកក្នុងផែនការពង្រីកកំណើនបរិយាបន្នបៃតងសំដៅពង្រឹងភាពធន់នៃសេដ្ឋកិច្ចកម្ពុជានាពេលអនាគត។”

ដោយមានការគាំទ្រពីគម្រោងសម្រាប់សេវាប្រឹក្សាការវិនិយោគបម្រែបម្រួលអាកាសធាតុ (Facility for Investment Climate Advisory Services, FIAS) គម្រោងនេះមានរយៈពេល ៣ឆ្នាំ ហើយប្រព័ន្ធវត្តិករសាស្ត្រហិរញ្ញវត្ថុជាតិ ត្រូវបានរំពឹងថានឹងដាក់ឱ្យដំណើរការនៅឆ្នាំ២០២៥។

## អំពីធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា គឺជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា។ បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយប្រាក់រៀលដែលជារូបិយវត្ថុជាតិ។ ធនាគារជាតិនៃកម្ពុជាជាអ្នករក្សាស្ថិរភាពរូបិយវត្ថុ។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាជាអ្នកផ្តល់និងដកហូតអាជ្ញាប័ណ្ណ ចេញបទប្បញ្ញត្តិនិងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រចាំ ចេញផ្សាយរបាយការណ៍ និងព្រឹត្តិបត្រផ្សេងៗ ត្រួតពិនិត្យប្រព័ន្ធទូទាត់ជាតិ ដំឡើងតារាងស្ថិតិជញ្ជីងទូទាត់ និងចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យក្រៅប្រទេស។

២

## អំពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ IFC

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ជាសមាជិករបស់ធនាគារពិភពលោក និងជាស្ថាប័នអភិវឌ្ឍពិភពលោកដ៏ធំបំផុតដែលផ្តោតលើវិស័យឯកជននៅក្នុងទីផ្សារកំពុងលូតលាស់។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) មានវត្តមាននៅក្នុងប្រទេសជាង ១០០ប្រទេស និងបានប្រើប្រាស់ដើមទុន ជំនាញ និងអានុភាពរបស់ខ្លួនដើម្បីជួយបង្កើតទីផ្សារ និងឱកាសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងឆ្នាំ២០២៣ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានផ្តល់ទឹកប្រាក់ចំនួន ៤៣,៧ ប៊ីលានដុល្លារអាមេរិកដល់ក្រុមហ៊ុនឯកជន និងគ្រឹះស្ថានហិរញ្ញវត្ថុក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីពង្រឹងសក្តានុពលនៃវិស័យឯកជនដើម្បីចូលរួមបញ្ចប់ភាពក្រីក្រខ្លាំង និងជំរុញវិបុលភាពរួមគ្នា ខណៈដែលសេដ្ឋកិច្ចកំពុងប្រឈមមុខនឹងផលប៉ះពាល់នៃវិបត្តិសកលលោក។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ www.ifc.org។

**ទំនាក់ទំនង៖**

**ធនាគារជាតិនៃកម្ពុជា**

ផ្នែកទំនាក់ទំនង

ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៨០ ១៩៦

អ៊ីម៉ែល៖ nbccommuniation@nbc.gov.kh

បណ្តាញផ្សព្វផ្សាយ៖

www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial, www.twitter.com/nbccambodia, www.instagram.com/nationalbankofcambodia, www.linkedin.com/company/national-bank-of-cambodia, www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA

**សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ**

Van Anh Chu, សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

ទូរស័ព្ទ៖ + 84 24 3937 8745

អ៊ីមែល៖ canh1@ifc.org




៣

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អមដំណើរសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ចូលក្រាបថ្វាយបង្គំគាល់ ព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រី



នាថ្ងៃសុក្រ ៥រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** បានសព្វព្រះរាជហឫទ័យព្រះបរមរាជានុញ្ញាតជូន **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងសហការី អមដំណើរ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុន ម៉ាណែត** ចូលក្រាបថ្វាយបង្គំគាល់ ដើម្បីក្រាបបង្គំទូលសួរពីព្រះរាជសុខភាព និងគោរពថ្វាយព្រះពរដល់ព្រះអង្គទាំងទ្វេ នៅព្រះមហាប្រាសាទខេមរិន្ទ ក្នុងព្រះបរមរាជវាំង។







*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងសហការី អមដំណើរ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុន ម៉ាណែត ចូលក្រាបថ្វាយបង្គំគាល់ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីក្រាបបង្គំទូលសួរពី ព្រះរាជសុខភាព និងគោរពថ្វាយព្រះពរដល់ព្រះអង្គទាំងទ្វេ នៅព្រះមហាប្រាសាទខេមរិន្ទ ក្នុងព្រះបរមរាជវាំង នាថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣*

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា និងឯកឧត្តម SAITO Ken អញ្ជើញចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ ស្តីពី "ការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរកូត


សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម KISHIDA Fumio នាយករដ្ឋមន្ត្រីនៃប្រទេសជប៉ុន

នាថ្ងៃចន្ទ ៦កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង **ឯកឧត្តម** SAITO Ken រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន អញ្ជើញចុះហត្ថលេខា លើអនុស្សរណៈ នៃកិច្ចសហប្រតិបត្តិការ ស្តីពី "ការទូទាត់ឆ្លងដែន តាមរយៈឃ្យូអរកូត (Unified QR Code-Based Payment)។ ពិធីចុះហត្ថលេខារៀបចំឡើងក្រោមសហ-អធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម** KISHIDA Fumio នាយករដ្ឋមន្ត្រី នៃប្រទេសជប៉ុន នៅក្នុងកិច្ចប្រជុំកំពូលកម្ពុជា-ជប៉ុន ដែលបានប្រព្រឹត្តិទៅនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣។ អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការនេះត្រូវបាន រៀបចំឡើងដើម្បីកំណត់ក្របខណ្ឌជាក់លាក់សម្រាប់ កិច្ចសហប្រតិបត្តិការលើកកម្ពស់សកម្មភាពប្រើប្រាស់ ប្រព័ន្ធទូទាត់ឆ្លងដែនតាម QR Code ដ៏ងាយស្រួល មានសុវត្ថិភាព និងប្រសិទ្ធភាព។ ក្របខណ្ឌកិច្ចសហ-ប្រតិបត្តិការនេះក៏នឹងចូលរួមលើកកម្ពស់ចរាចរណ៍ រូបិយវត្ថុជាតិ ព្រមទាំងជំរុញវិស័យទេសចរណ៍រវាង ប្រទេសទាំងពីរឱ្យកាន់តែមានសក្តានុពលថែមទៀត ផងដែរ។





# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូចូលរួមក្នុងមហាសន្និបាតពេញអង្គប្រចាំឆ្នាំ២០២៣ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (WB) នៅទីក្រុងម៉ារ៉ាកិច ប្រទេសម៉ារ៉ុក




នាថ្ងៃចន្ទ ១០រោច ខែភទ្របទ ដល់ថ្ងៃអាទិត្យ ១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៩-១៥ ខែតុលា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូចូលរួមក្នុងមហាសន្និបាតពេញអង្គប្រចាំឆ្នាំ២០២៣ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (WB) នៅទីក្រុងម៉ារ៉ាកិច ប្រទេសម៉ារ៉ុក។ ការចូលរួមនេះ បង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការពង្រឹងកិច្ចសហការរវាងកម្ពុជា IMF និង WB ឱ្យកាន់តែរឹងមាំ សម្រាប់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា ក៏ដូចជាផ្តល់ឱកាសក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីជាមួយប្រទេសជាសមាជិកដទៃថែមទៀតផងដែរ។ មហាសន្និបាតឆ្នាំនេះ មានការចូលរួមជាចម្បងពីសំណាក់ទេសាភិបាលធនាគារកណ្តាល និងរដ្ឋមន្ត្រីហិរញ្ញវត្ថុ ដែលជាតំណាងពីប្រទេសសមាជិកនៅក្រុមប្រឹក្សាទេសាភិបាលនៃស្ថាប័នអន្តរជាតិទាំងពីរ។ គោលបំណងចម្បងនៃមហាសន្និបាតនេះ គឺដើម្បីផ្សព្វផ្សាយពីវឌ្ឍនភាពការងារនិងទស្សនវិស័យរបស់ IMF និង WB ដែលបង្ហាញពីលទ្ធភាពនៃការជួយពង្រឹងបន្ថែមទៀតក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាសមាជិក។ ទន្ទឹមនេះ វេទិកាពាក់ព័ន្ធនានាក៏ត្រូវបានរៀបចំផងដែរ ដើម្បីផ្តល់ជាវេទិកាពិភាក្សាពីស្ថានភាពនិងបញ្ហាប្រឈមនៃសេដ្ឋកិច្ចពិភពលោកនិងតំបន់។ ប្រធានបទចម្បងៗដែលបាននិងកំពុងយកចិត្តទុកដាក់ពី IMF និង WB រួមមាន ការលុបបំបាត់ភាពក្រីក្របំផុតនៅលើពិភពលោក វិសមភាពចំណូល ការអភិវឌ្ឍនិងហិរញ្ញប្បទានបៃតង បញ្ហាអាកាសធាតុ ការអនុវត្តនយោបាយរូបិយវត្ថុវិត្ថារកម្ម ឌីជីថលូបនីយកម្ម ជាដើម។ គួរកត់សម្គាល់ថា កន្លងមក IMF និង WB បានដើរ





តួនាទីយ៉ាងសំខាន់ក្នុងការជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា តាមរយៈការផ្តល់ជំនួយបច្ចេកទេស ហិរញ្ញប្បទាន អាហារូបករណ៍ក្នុងការអភិវឌ្ឍធនធានមនុស្ស តាមដាននិងការវាយតម្លៃសេដ្ឋកិច្ច និងការផ្តល់អនុសាសន៍គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាដើម។ ទន្ទឹមនេះ កម្ពុជា ជាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលទទួលបានអត្ថប្រយោជន៍ក្នុងរូបភាពជាជំនួយបច្ចេកទេសច្រើនជាងគេពី IMF ផងដែរ។ ឆ្លៀតក្នុងឱកាសនោះ លោកជំទាវបណ្ឌិត ទេសាភិបាល បានជួបពិភាក្សាការងារទ្វេភាគីជាមួយភាគីពាក់ព័ន្ធនានា ជាពិសេស កិច្ចប្រជុំទ្វេភាគីនឹងធនាគារកណ្តាលម៉ារ៉ុក ដែលលោកជំទាវនិង **ឯកឧត្តម** Abdellatif Jouahri ទេសាភិបាល ធនាគារកណ្តាលម៉ារ៉ុក បានឯកភាពគ្នាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការលើបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលក្នុងនោះមានប្រព័ន្ធទូទាត់ និងរូបិយប័ណ្ណឌីជីថល ជាដើម។ ជាមួយគ្នានេះ លោកជំទាវបណ្ឌិតក៏បានជួបប្រជុំទ្វេភាគីជាមួយ **ឯកឧត្តម** Perry Warjiyo ទេសាភិបាលធនាគារកណ្តាលឥណ្ឌូណេស៊ី ដើម្បីពិភាក្សាពីចុះអនុស្សរណៈយោគយល់ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីថែមទៀត ជាពិសេសលើការតភ្ជាប់ប្រព័ន្ធទូទាត់អេឡិចត្រូនិកឆ្លងដែន ដែលនឹងសម្រួលដល់ទេសចរណ៍ ការធ្វើពាណិជ្ជកម្ម និងការវិនិយោគក្នុងប្រទេសទាំងពីរ។ ភាគីទាំងពីរក៏បានយល់ព្រមក្នុងការលើកកម្ពស់ការផ្លាស់ប្តូរបទពិសោធន៍លើការអនុវត្តនយោបាយរូបិយវត្ថុ ការងារស្ថិតិ និងប្រតិបត្តិការរបស់សាខាធនាគារកណ្តាលតាមបណ្តារាជធានី-ខេត្ត។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូ ចូលរួមក្នុងកិច្ចប្រជុំលើកទី៤ របស់គណៈកម្មការគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ

នាថ្ងៃពុធ ៣រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូចូលរួមក្នុងកិច្ចប្រជុំលើកទី៤របស់គណៈកម្មការគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍរបស់អង្គការយូអិនអេស្កាប់ (UNESCAP) នៅទីក្រុងបាងកក ប្រទេសថៃ។ លោកជំទាវ បានថ្លែងនៅក្នុងកម្មវិធីបើកនៃកិច្ចប្រជុំនេះថា ធនាគារជាតិនៃកម្ពុជាបាននិងកំពុងខិតខំធ្វើយ៉ាងណាឱ្យប្រព័ន្ធធនាគារនៅកម្ពុជា អាចដើរតួនាទីសំខាន់ក្នុងការកៀងគរហិរញ្ញប្បទាន ដើម្បីគាំទ្រដល់គោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅសម្រេច



ឱ្យបានតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែលប្រួលអាកាសធាតុ។ គួររំលេចថា ធនាគារជាតិនៃកម្ពុជាបានបង្កើតឱ្យមានគំនិតផ្តួចផ្តើមជាច្រើនក្នុងការរៀបចំយន្តការគាំទ្រហិរញ្ញប្បទានប្រកបដោយចីរភាព ដែលក្នុងនោះរួមមាន ការរៀបចំឱ្យមានផែនទីចង្អុលផ្លូវសម្រាប់ការជំរុញហិរញ្ញប្បទានប្រកបដោយចីរភាព ការបង្កើតឱ្យមានវដ្តករសាស្រ្ត





*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង លោកជំទាវ Armida Salsiah Alisjahbana អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាអគ្គលេខាធិការអង្គការយូអិនអេស្កាប់*

សម្រាប់គាំទ្រលំហូរមូលធន ការដាក់ចេញនូវក្របខណ្ឌនៃការរាយការណ៍ និងការកសាងសមត្ថភាព ជាដើម។ លោកជំទាវក៏បានស្នើឱ្យប្រទេសដែលងាយរងគ្រោះបង្កើនសកម្មភាពរបស់ខ្លួនក្នុងការជំរុញហិរញ្ញប្បទានសម្រាប់គាំទ្រដល់ការពង្រឹងភាពធន់ និងអាចសម្របសម្រួលជាមួយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះ លោកជំទាវបណ្ឌិត ទេសាភិបាលក៏បានជួបប្រជុំទ្វេភាគីជាមួយ **លោកជំទាវ Armida Salsiah Alisjahbana** អគ្គលេខាធិការរងអង្គការសហប្រជាតិ និងជាអគ្គលេខាធិការអង្គការយូអិនអេស្កាប់ ដើម្បីពិភាក្សាពីកិច្ចសហប្រតិបត្តិការដែលកំពុងអនុវត្ត និងស្វែងរកគំនិតផ្តួចផ្តើមបន្ថែមទៀតក្នុងការជំរុញការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាពសម្រាប់គម្រោងនិងការវិនិយោគទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។ លោកជំទាវ និងសមភាគី បានឯកភាពលើចំណុចសំខាន់ក្នុងការជំរុញលំហូរមូលធនដើម្បីបង្កើនការវិនិយោគបៃតង និងប្រកបដោយចីរភាព នៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍន៍។ ដូច្នេះ អ្នកវិនិយោគត្រូវពិនិត្យនូវលក្ខខណ្ឌ និងតម្រូវការរបស់ខ្លួនឱ្យស្របតាមស្ថានភាព និងលទ្ធភាពជាក់ស្តែងរបស់ប្រទេសទាំងនោះ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីចូលរួមក្នុងកិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោកជំទាវ Nguyen Thi Hong ទេសាភិបាល ធនាគាររដ្ឋវៀតណាម*

នៅថ្ងៃអាទិត្យ ៦រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជារៀបចំកិច្ចប្រជុំទ្វេភាគីរវាង ធនាគារជាតិនៃកម្ពុជា និងធនាគាររដ្ឋវៀតណាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង **លោកជំទាវ** Nguyen Thi Hong ទេសាភិបាល ធនាគាររដ្ឋវៀតណាម នៅខេត្តសៀមរាប។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងនៅក្នុងគោលបំណងរឹតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងធនាគារកណ្តាលទាំងពីរ។ ក្នុងឱកាសនោះ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងលោកជំទាវ Nguyen Thi Hong ទេសាភិបាល ធនាគាររដ្ឋវៀតណាម ក៏បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូត (QR Code) រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ ការដាក់ឱ្យដំណើរការការទូទាត់ឆ្លងដែនតាមយូអរកូត (QR Code) នេះនឹងជំរុញការទូទាត់ឌីជីថល និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិប្រកបដោយភាពងាយស្រួល ឆាប់រហ័ស តម្លៃសមរម្យ សុវត្ថិភាព ជំរុញកំណើនសេដ្ឋកិច្ច ទេសចរណ៍ និងពាណិជ្ជកម្មឆ្លងដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងវេទិកាសន្ទនាកម្រិតអ្នករៀបចំគោលនយោបាយ ក្នុងកម្មវិធីតាំងពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ឆ្នាំ២០២៣

នាថ្ងៃសុក្រ ៥កើត ខែកត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងវេទិកាសន្ទនាកម្រិតអ្នករៀបចំគោលនយោបាយ ដើម្បីពិភាក្សាអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន ដែលរៀបចំឡើងនៅក្នុងកម្មវិធីតាំងពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី ឆ្នាំ២០២៣ នៅប្រទេសសិង្ហបុរី។ នាឱកាសនោះ លោកជំទាវបណ្ឌិត បានបង្ហាញពីដំណើរការអភិវឌ្ឍន៍ បញ្ហាប្រឈម និងកាលានុវត្តភាពសំខាន់ៗក្នុងវិស័យហិរញ្ញវត្ថុឌីជីថលនៅកម្ពុជា។ កិច្ចសន្ទនានេះក៏មានវត្តមានចូលរួមរបស់វាគ្មិនល្បីៗដទៃទៀត រួមមាន **ឯកឧត្តម** John Rwangombwa អគ្គទេសាភិបាល ធនាគារកណ្ដាលប្រទេសរវ៉ាន់ដា និង **ឯកឧត្តម** Khalid Humaidan នាយកប្រតិបត្តិ ក្រុមប្រឹក្សាអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេស Bahrain ផងដែរ។ នៅក្នុងកម្មវិធីពិព័រណ៍បច្ចេកវិទ្យាហិរញ្ញវត្ថុ



ដដែលនេះ លោកជំទាវបណ្ឌិត ទេសាភិបាល ក៏បានអញ្ជើញចូលរួមក្នុងកិច្ចពិភាក្សាអាហារថ្ងៃត្រង់ ស្ដីពី "ស្ត្រីនៅក្នុងភាពជាអ្នកដឹកនាំ (Lunch and Learn: Women in Leadership)" ដែលក្នុងកិច្ចពិភាក្សានេះ លោកជំទាវបណ្ឌិត ក៏ដូចជាស្ត្រីជាថ្នាក់ដឹកនាំដ៏មានឥទ្ធិពលដទៃទៀត បានរៀបរាប់ និងចែករំលែកបទពិសោធន៍អំពីដំណើរជីវិត ឧបសគ្គដែលបានឆ្លងកាត់ ក៏ដូចជាចំណុចគន្លឹះៗដែលបង្ហាញថា ស្ត្រីគឺជាកម្លាំងចលករដ៏សំខាន់ក្នុងការផ្លាស់ប្ដូរជាវិជ្ជមាននៅក្នុងស្ថាប័ន-អង្គភាព ក៏ដូចជាសបញ្ជាក់ថាការរួមចំណែករបស់ស្ត្រីពិតជាមានសារៈសំខាន់សម្រាប់អនាគតដ៏វែងឆ្ងាយរបស់គ្រួសារ និងសង្គមជាតិ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមក្នុងសន្និសីទអន្តរជាតិ MOEF-BOK-FSC-IMF ឆ្នាំ២០២៣ ក្រោមមូលបទ រូបិយប័ណ្ណឌីជីថល

នាថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមក្នុងសន្និសីទអន្តរជាតិ MOEF-BOK-FSC-IMF ឆ្នាំ២០២៣ ក្រោមមូលបទ រូបិយប័ណ្ណឌីជីថល ដោយផ្តោតលើយុទ្ធសាស្ត្រកែប្រែទិដ្ឋភាពហិរញ្ញវត្ថុ (Navigating a Changing Financial Landscape) នៅទីក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ។ រូបិយប័ណ្ណឌីជីថលបានក្លាយជាប្រធានបទគួរឱ្យចាប់អារម្មណ៍កម្រិតពិភពលោកនៅប៉ុន្មានឆ្នាំចុងក្រោយនេះ តាមរយៈអត្ថប្រយោជន៍យ៉ាងច្រើនរបស់រូបិយប័ណ្ណឌីជីថល ដូចជា ជំរុញផលិតភាពផលិតកម្ម និងសេដ្ឋកិច្ចឱ្យរីកចម្រើនជាដើម។ លើសពីនេះទៀត រូបិយប័ណ្ណឌីជីថលក៏បានចូលរួមបង្កើនប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្ម កាត់បន្ថយចំណាយថ្លៃដើម និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ទន្ទឹមគ្នានេះដែរ រូបិយប័ណ្ណឌីជីថលក៏អាចមានហានិភ័យមួយចំនួនផងដែរទៅលើស្ថិរភាពហិរញ្ញវត្ថុ និងកិច្ចការពារអ្នកប្រើប្រាស់រូបិយប័ណ្ណ។ សន្និសីទបានប្រមូលផ្តុំគំនិតសំខាន់ៗរបស់អ្នកជំនាញ អ្នកបង្កើតគោលនយោបាយ និងអ្នកសិក្សាស្រាវជ្រាវមកពីជុំវិញពិភពលោក ដើម្បីចែករំលែកបទពិសោធន៍ និងពិភាក្សាលើបញ្ហាគោលនយោបាយសំខាន់ៗជុំវិញរូបិយប័ណ្ណឌីជីថល។ នៅក្នុងសន្និសីទនេះដែរ លោកជំទាវបណ្ឌិត ជា សិរី ក៏បានចែករំលែកទស្សនៈរបស់លោកជំទាវទាក់ទងនឹងរូបិយប័ណ្ណឌីជីថល ដោយសារតែប្រទេសកម្ពុជាបានអភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធបាគងរួចហើយ ហើយប្រព័ន្ធនេះក៏អាចត្រូវបានចាត់ទុកជាទម្រង់មួយនៃរូបិយប័ណ្ណឌីជីថលផងដែរ ពីព្រោះប្រព័ន្ធនេះមានចំណុចពិសេសៗស្រដៀងគ្នានឹងរូបិយប័ណ្ណឌីជីថលធនាគារកណ្តាល (DBDC) ដែរ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម Cherdkiat Atthakor ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំព្រះរាជាណាចក្រកម្ពុជា



នាថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារជាមួយ **ឯកឧត្តម** Cherdkiat Atthakor ឯកអគ្គរាជទូតព្រះរាជាណាចក្រថៃប្រចាំព្រះរាជាណាចក្រកម្ពុជា នៅធនាគារជាតិនៃកម្ពុជា។ កិច្ចពិភាក្សាក្នុងជំនួបនេះ បានផ្តោតសំខាន់លើកិច្ចការលើកកម្ពស់កិច្ចសហប្រតិបត្តិការរបស់ប្រទេសទាំងពីរនាពេលកន្លងមក និងការផ្លាស់ប្តូរទស្សនៈពីគំនិតផ្តួចផ្តើមថ្មីៗ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំថែមទៀត សំដៅរួមចំណែកដល់ការរីកចម្រើនវិស័យធនាគារនិងសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរ។ ឯកឧត្តមឯកអគ្គរាជទូតបានយកឱកាសនេះអបអរសាទរ លោកជំទាវបណ្ឌិត ជា សិរី ក្នុងតួនាទីជាទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងបានរំលេចពីភាពលេចធ្លោរបស់លោកជំទាវ ដែលតែងផ្តួចផ្តើមបង្កើតគម្រោងថ្មីៗប្រកបដោយនវានុវត្តន៍ ដើម្បីអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា។ ឯកឧត្តម បានលើកឡើងថា ការណ៍នេះមិនត្រឹមតែបានពង្រឹងភាពរឹងមាំនៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាប៉ុណ្ណោះ តែថែមទាំងរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរជាពិសេសខាងផ្នែកហិរញ្ញវត្ថុ។ ឯកឧត្តម Cherdkiat Atthakor ក៏បានថ្លែងកោតសរសើរដល់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ដែលបានខិតខំយ៉ាងខ្លាំងនៅក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល តាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិនានា និងយុទ្ធនាការផ្សព្វផ្សាយជាច្រើន រួមទាំងការបង្កើតសារៈមន្ទីរព្រះស្រីឦសានវរ្ម័នដែលបានលើកកម្ពស់ការយល់ដឹងរបស់សាធារណជនពី







អត្ថប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល និងប្រវត្តិសេដ្ឋកិច្ចនិងរូបិយវត្ថុកម្ពុជា។ លោកជំទាវបណ្ឌិត ជា សិរី បានបញ្ជាក់ជូនថា ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃបានពង្រឹងកិច្ចសហប្រតិបត្តិការយ៉ាងល្អលើផ្នែកជាច្រើនដូចជា ការផ្លាស់ប្តូរទស្សនកិច្ចចែករំលែកបទពិសោធន៍លើការងារជំនាញ ការទទួលអាហារូបករណ៍សម្រាប់មន្ត្រីធនាគារជាតិនៃកម្ពុជាទៅសិក្សាថ្នាក់ឧត្តមសិក្សានៅប្រទេសថៃ និងជាពិសេសកិច្ចសហការលើការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែន។ ជាក់ស្តែង ប្រទេសថៃ គឺជាប្រទេសដំបូងគេដែលប្រទេសកម្ពុជាបានតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែន ដែលកិច្ចសហការនេះបានរួមចំណែកយ៉ាងសំខាន់ដល់ការគាំទ្រពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ក្នុងប្រទេសទាំងពីរ ព្រមទាំងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិក្នុងទីផ្សារស្របទៅតាមគោលដៅសហគមន៍សេដ្ឋកិច្ចអាស៊ាន។ លោកជំទាវក៏បានបន្ថែមថា ធនាគារកណ្តាលទាំងពីរបាននិងកំពុងអភិវឌ្ឍប្រព័ន្ធផ្ទេរប្រាក់សម្រាប់ពលករកម្ពុជាដែលកំពុងធ្វើការនៅប្រទេសថៃដើម្បីឱ្យការផ្ទេរមកកាន់ក្រុមគ្រួសារនៅកម្ពុជាប្រកបដោយសុវត្ថិភាពឆាប់រហ័ស និងចំណាយទាប។ មិនត្រឹមតែប៉ុណ្ណោះ លោកជំទាវទេសាភិបាល ក៏បានលើកឡើងពីគម្រោងពង្រីកកិច្ចសហប្រតិបត្តិការសម្រាប់ការចែករំលែកព័ត៌មានឥណទានអតិថិជនរវាងប្រទេសកម្ពុជានិងថៃដើម្បីលើកកម្ពស់ការផ្តល់ឥណទានប្រកបទៅដោយការទទួលខុសត្រូវនិងប្រសិទ្ធភាពខ្ពស់។ ស្របពេលដែលវិស័យហិរញ្ញវត្ថុប្រទេសទាំងពីរបន្តអភិវឌ្ឍយ៉ាងឆាប់រហ័ស លោកជំទាវ ទេសាភិបាល មានសុទិដ្ឋិនិយមថា ធនាគារកណ្តាលប្រទេសទាំងពីរនឹងបន្តពង្រីកកិច្ចសហប្រតិបត្តិការកាន់តែសម្បូរបែប ថែមទៀតនាពេលខាងមុខ។ ឯកឧត្តមឯកអគ្គរាជទូត បានសម្តែងការគាំទ្រ និងត្រៀមខ្លួនក្នុងការពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងធនាគារកណ្តាលទាំងពីរឱ្យកាន់តែរឹងមាំ។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូចូលជួបប្រជុំពិភាក្សាការងារជាមួយអនុគណៈកម្មការរដ្ឋសភា



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*ឯកឧត្តម ឈាង វុន ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា*

នាថ្ងៃសុក្រ ៦កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូចូលជួបប្រជុំពិភាក្សាការងារជាមួយអនុគណៈកម្មការរដ្ឋសភា ដែលដឹកនាំដោយ **ឯកឧត្តម ឈាង វុន** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា។ គោលបំណងនៃកិច្ចប្រជុំពិភាក្សានេះ គឺដើម្បីជម្រាបជូនដល់អនុគណៈកម្មការពីវឌ្ឍនភាពនៃប្រព័ន្ធធនាគារ និងតួនាទីនិងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនោះ លោកជំទាវក៏បានអញ្ជើញគណៈប្រតិភូអនុគណៈ-កម្មការនៃរដ្ឋសភាមកទស្សនាសារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីល្បសានវរ្ម័ន ដើម្បីស្វែងយល់បន្ថែមអំពីប្រវត្តិនៃរូបិយវត្ថុនិងសេដ្ឋកិច្ចកម្ពុជា។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគណៈប្រតិភូនៃធនាគារកណ្តាលប្រទេសប៉ាពួញ៉ូហ្គីណេ កោះសូឡូម៉ូន និងប្រទេសវ៉ានូទូចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

នាថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគណៈប្រតិភូនៃធនាគារកណ្តាលប្រទេសប៉ាពួញ៉ូហ្គីណេ កោះសូឡូម៉ូន និងប្រទេសវ៉ានូទូចូលជួបសម្តែងការគួរសម និងពិភាក្សាការងារពាក់ព័ន្ធនឹងភាពជោគជ័យរបស់កម្ពុជា ក្នុងការរៀបចំ និងគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងប្រព័ន្ធបាគង។ ជាមួយគ្នានេះដែរ មន្រ្តីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា បានចែករំលែកនូវបទពិសោធន៍ល្អៗ និងភាពជោគជ័យ



ជូនដល់គណៈប្រតិភូ រួមមាន ការផ្តល់អាជ្ញាបណ្ណ វិធី-សាស្រ្តក្នុងការត្រួតពិនិត្យ សវនកម្ម និងការអភិវឌ្ឍព័ត៌មានឥណទានឆ្លងដែន ព្រមទាំងប្រវត្តិនិងការបង្កើតប្រព័ន្ធទូទាត់បាគង ផងដែរ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបក្រុមបេសកកម្មមាត្រា IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)



*លោក Davide Furceri ជាប្រធានក្រុមបេសកកម្មមាត្រា IV មូលនិធិរូបិយវត្ថុអន្តរជាតិ*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*

នាថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំថោះ ចត្វាស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបក្រុមបេសកកម្មមាត្រា IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយ **លោក** Davide Furceri ជាប្រធានក្រុមបេសកកម្ម ដែលកំពុងបំពេញបេសកកម្មនៅកម្ពុជា ចាប់ពីថ្ងៃទី១៨ ដល់ ៣១ ខែតុលា ឆ្នាំ២០២៣។ បេសកកម្មនេះត្រូវបានធ្វើឡើងដើម្បីតាមដានស្ថានភាពសេដ្ឋកិច្ចកម្ពុជាប្រចាំឆ្នាំ២០២៣ និងទស្សនៈវិស័យអនាគត។ លោកជំទាវ បានសម្តែងការស្វាគមន៍ចំពោះវត្តមានរបស់ក្រុមបេសកកម្ម ដែលតែងតែផ្តល់ការវាយតម្លៃស៊ីជម្រៅមកលើវឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ច និងលើកឡើងពីអនុសាសន៍គោលនយោបាយ សម្រាប់ជាជម្រើសក្នុងការអនុវត្ត ដើម្បីគាំទ្រការអភិវឌ្ឍនិងពង្រឹងភាពធន់នៃសេដ្ឋកិច្ចកម្ពុជា។ លោកជំទាវ បានជម្រាបជូនផងដែរ ពីវឌ្ឍនភាពសេដ្ឋកិច្ចកម្ពុជា និងបញ្ហាប្រឈម ព្រមទាំងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដែលរាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្ត សំដៅគាំទ្រការងើបឡើងនៃសេដ្ឋកិច្ច និងទប់ទល់នឹងហានិភ័យនានា ជាពិសេសដោយសារភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក។ ឆ្លៀតក្នុងឱកាសនេះ លោកជំទាវ ទេសាភិបាល ក៏បានថ្លែងអំណរគុណចំពោះ IMF ដែលតែងផ្តល់ជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលនានា ដែលបានរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្ស។ លោកជំទាវ ក៏បានអនុញ្ញាតឱ្យថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ ពិភាក្សាលម្អិតជាមួយក្រុមបេសកកម្ម ដើម្បីផ្លាស់ប្តូរការវាយ-តម្លៃ និងផ្តល់ជាព័ត៌មាន និងទិន្នន័យបន្ថែមដល់ក្រុមបេសកកម្ម។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ជួបសម្តែងការគួរសម និងជម្រាបជូនអំពីវឌ្ឍនភាពនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

នៅថ្ងៃព្រហស្បតិ៍ ៥កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាលនៃសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ជួបសម្តែងការគួរសម និងជម្រាបជូនអំពីវឌ្ឍនភាពនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ បន្ទាប់ពី លោកជំទាវ ទេសាភិបាល បានជ្រាបអំពីវឌ្ឍនភាព បញ្ហាប្រឈម និងសំណូមពររបស់សមាគម លោកជំទាវ ទេសាភិបាល បានផ្តល់នូវអនុសាសន៍ដល់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក្នុងការចូលរួមអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ រួមមាន ១/- លើកកម្ពស់ភាពធន់ និងនិរន្តរភាពរបស់សមាជិកនិងវិស័យ ២/- បង្កើនចំណេះដឹងហិរញ្ញវត្ថុ និងឥរិយាបថជាវិជ្ជមានចំពោះវិស័យមីក្រូហិរញ្ញវត្ថុដល់អតិថិជន និងសាធារណជន ៣/- ពង្រឹងសមត្ថភាពធនធានមនុស្ស និងការអនុវត្តស្របតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងការផ្តល់ឥណទាន ៤/- ត្រូវសិក្សា និងចងក្រងជាឯកសារអំពីក្រុមហ៊ុនផ្តល់ឥណទានខុសច្បាប់ មុននឹងស្នើសុំអន្តរាគមន៍ពីអាជ្ញាធរពាក់ព័ន្ធ និង ៥/-សូមលើកទឹកចិត្តបន្តវប្បធម៌សន្ទនាឱ្យបានច្រើន និងជាប្រចាំរវាងវិស័យឯកជន និងអាជ្ញាធរ ដែលជាការបង្ហាញអំពីការសហការគ្នាក្នុងការដោះស្រាយបញ្ហា និងជំរុញការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ដឹកនាំកិច្ចប្រជុំ ស្តីពី "ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ "ក្រុម ង" នៃវេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន"

នាថ្ងៃចន្ទ ៩កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ដឹកនាំកិច្ចប្រជុំ ស្តីពី "ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ "ក្រុម ង" នៃវេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន" ដោយមានការចូលរួមពីសំណាក់វិស័យឯកជន ក្រសួង-ស្ថាប័នពាក់ព័ន្ធ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងតំណាងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះ មានគោលបំណងដោះស្រាយសំណើ និងការប្រឈមនានារបស់វិស័យធនាគារ




